# សំលេងខ្សែអាត់ សម្តេច ជួបជាមួយឯកឧត្តម សុន ឆ័យ
## ថ្ងៃទី១៧-១០-៩៧ (ម៉ោង ៧:៣០នាទីយប់)

* * * * *

**សុន ឆ័យ**: ឥឡូវហ្នឹងជំរាបជូន... មកដល់គេអត់មានថាម៉េចទេ..... នេះទៅគឺប៉ុន្មានថ្ងៃហ្នឹង គេធ្វើ draft ពីរឿង Condition លក្ខន្តិកៈលក្ខខណ្ឌនេះ ដើម្បីនឹងចូលមកប្រទេសវិញដោយរួមគ្នា នេះគឺជាពេលដែល តាមខ្ញុំដឹងអារបស់ដែលគេធ្វើហ្នឹង គឺរៀបចំឡើងដោយ IRI និង NDI ហ្នឹង ពីព្រោះពួកនៅក្រៅ វាទៅដេកនៅអាអូតែល Black Side អីនោះ ។

**សម្តេច** : ពិនិត្យមើលទៅថាតើសភាពការណ៍ខាងក្រៅយ៉ាងម៉េច ?

**សុន ឆ័យ**: ខ្ញុំសូមជំរាបអញ្ចេះ...... ប្រហែលជាខ្ញុំមិនដែលហ៊ានទៅទេ ព្រោះពួកនេះវាមិនដែលទុកចិត្តខ្ញុំផង ហើយដូច្នេះអត់សូវដឹងរឿង....គ្រាន់តែ បើពិនិត្យមើលទៅគឺថា ព្រោះការពិតទៅ... សភាពការណ៍ខ្ញុំមិនសូវនិយាយ... ឥឡូវវាពិបាកបន្តិចត្រង់ថានៅក្រៅ ដូច្នេះខ្ញុំមើលទៅឃើញថា ជប៉ុនវារាងផ្លាស់ប្តូរដែរ អាតាំងវាដើរអង្រួន សម្តេច មិនដឹងជារឿងអីទេ ម្ល៉ោះហើយថាតើយើងគួរធ្វើយ៉ាងម៉េចឱ្យមានភាពទុនភ្ជួនខ្លះ ឧទាហរណ៍ចំណុចដែលគេចាប់អារម្មណ៍ខ្លះ ដូចជាបញ្ហាអ្នកណាអ្នកការពារ... គេជឿទាំងស្រុង ហើយគេផ្តោតការ អ្នកដែលថាពាក់ព័ន្ធរឿងនេះ ពុំបានត្រូវផ្តន្ទាទោសទេ បានន័យថាបងការពារ បើយើងការពារទៅបញ្ញាស់គ្នាទេ ដើម្បីកុំឱ្យពួកនឹងវាតាម វាពិបាកអាកិច្ចការហ្នឹង វាពិបាក ខ្ញុំធ្វើអីអត់កើត ។ បើពួកហ្នឹងដាក់សំណើមក សំណើនោះខ្ញុំជំរាបបងត្រង់ហើយ សំណើនោះ ថ្ងៃដែលខ្ញុំមកនោះគឺគេអត់ឱ្យមកទេ ដូច រង្សី អញ្ជឹង រង្សី គាត់ចង់មក គំនិតគាត់មកដល់គាត់មកមើលអញ្ជឹងទៅ រួចហើយចេញទៅវិញ គេធ្វើសន្និសិទកាសែតមួយដែរទៅ ថាស្រុកខ្មែរហ្នឹងវាអត់មានស្អី១អញ្ជឹងយកល្បីឈ្មោះទៅណា ។ ដល់អញ្ជឹងមើលទៅរាងពិបាក ខ្ញុំសំរេចថាមកល្ងាចហ្នឹង គេអត់ឱ្យខ្ញុំទៅប្រាប់ ប្រាប់មកថា ហេតុអីបានជាខ្ញុំចង់មក ពន្យល់គេ វាមានតាមួយ តាអីជូត១ក្បាលនឹងកន្សែងនៅកន្លែង ។

**សម្តេច** : ឡឹន ម៉ាក់

**សុន ឆ័យ**: ឡឹន ម៉ាក់ ហ្នឹង តាហ្នឹងគាត់ទើបតែល្បីឈ្មោះ រួចគាត់ទៅ មិនដឹងជាគាត់ទៅស៊ីសស៊ុះអីគាត់ជាសមាជិករបស់..... ដែលគាត់ធ្លាប់ជួប.... រួចតានោះគាត់និយាយថាមិនត្រូវមកទេ វាអត់ស្រួលទេ សុទ្ធតែអី១មក.... សម្តេចទី២លោកពីដើមជាឧបករណ៍.... ម៉េច សុន ឆ័យ មកបាន ? ម៉េចអ្នកដទៃមកមិនបានអីណា វាខូចដល់សេចក្តីព្រៀងរបស់គេនោះ ដែលគេមាននៅនឹងដៃ ដែលយកមក ហើយខ្ញុំដល់អញ្ជឹងខ្ញុំតវាថាខ្ញុំទៅ គឺទូរស័ព្ទទៅអាមេរិក ដល់ម៉ោង២:០០យប់ម៉ិញនេះ ខ្ញុំគេងកឹម សុខា វាទូរស័ព្ទមកជេរខ្ញុំថា ហ៊ឺ! ហ្អែងទៅ១ ហ្អែងទៅបំរើគេទៅ ហ្អែងភ្លេចបងហ្អែងហើយ វានិយាយអញ្ជឹង រួចចុះ.... ម៉ោង៦:០០ទៀត វាថាហ្អែងទៅហើយ ទៅ១ ទៅសំលាញ់ហ្អែងទៅឱ្យបាត់ទៅ។ ...ជារឿងមួយដែលត្រូវមើលឃើញ តើយើងអាចលែលកបែបម៉េច ជារូបភាពខាងក្រៅហ្នឹង ដើម្បីកុំឱ្យវាមានកាល១ ពួកហ្នឹងវាបានចេះតែមានគំនិតចេះជំរុញយើង បុកយើង បើមានបញ្ហាយើងវា

ថាយើងហ្នឹងវារំលោភគេ យើងហ្នឹងវាអាក្រក់ យើងហ្នឹងវាចិត្តអាក្រក់ណាស់ វាមិនដឹងថា បើគ្មានស្ពានការណ៍ថ្ងៃនេះ តើស្រុកខ្មែរវាទៅជាយ៉ាងម៉េច ? ទៅមុខក៏មិនរួច ទៅក្រោយក៏មិនរួច អ្នកណាក៏មិនដោះស្រាយ រួចក្រុមព្រះហ្នឹងបង្កើតតែអាល្បែងដែលក្រុមព្រះ គេថតយកបានអាដែលថាបាញ់អីគាត់នោះ គេលើកភស្តុតាងហ្នឹងទៅយកអាហ្នុងទៅប្រាប់គេ វាគិតតែឃើញកំហុសយើង ។ តើយើងធ្វើយ៉ាងម៉េច ? ខ្ញុំគិតថាគួរតែបើកអញ្ចឹងតែម្តង ពីព្រោះខ្ញុំនិយាយថាក្រុមព្រះយ៉ាងមក ឧបមាថាឥឡូវមើលចង់ថាម៉េច ចង់បានយ៉ាងម៉េច យកមកជជែកគ្នាមក ឥឡូវខ្ញុំធ្វើប្រកាសមុនសិនចាំជជែកគ្នាទៀត មកជជែកគ្នា ពីព្រោះបើតាមខ្ញុំមើលទៅពួកហ្នុងប្រហែលជាជាងមួយខែទៀតទ្រាំអត់បានចាប់ផ្តើមរប៉ាត់រប៉ាយ ៦អាទិត្យអីទៀតហ្នឹងគាត់រប៉ាត់រប៉ាយហើយ។ ពីព្រោះ ឥឡូវនេះគេមិនដឹងជាបង្កើតឬយ៉ាងម៉េចទេ ? មានតែម្តងមួយទៅ.... សម្តេច ហ៊ុន សែន ឥឡូវមិនគួរទៅវៃគាត់អី....... វៃគាត់អីៗ ជិតបានហើយ។ រាល់ថ្ងៃហ្នឹងវាមានជួយយកគំនិតហ្នឹង ទៅដើម្បីឱ្យពួកហ្នុងចេះតែទុកចិត្តឡើងដូច មិន សារឿន និង យុន គីណុប នេះ ពីមុនក៏មានទាក់ទងមកនេះ ដើម្បីថាចង់យកគ្នាប៉ុន្មាននាក់ទៅ ទៅឱ្យក្រុមព្រះ រួមក្រុមព្រះចាត់២នាក់ហ្នឹងមកឱ្យ ទាក់ទងមក ។ តែតាមការពិតទៅនិយាយលេងទេ គាត់អរពេកគាត់ទៅប្រាប់ខ្ញុំអញ្ចឹង ចិត្តគាត់ហ្នឹងក៏រាងពិបាកដែរ ប៉ុន្តែស្រាប់តែប៉ុន្មានថ្ងៃនេះគាត់ទៅខេត្តត្រាត ។

**សម្តេច** : ខេត្តត្រាត

**សុន ឆ័យ** : កន្លែងជិតកោះកុងហ្នឹង ខេត្តត្រាត ។

**សម្តេច** : ខេត្តត្រាត

**សុន ឆ័យ** : ខេត្តត្រាត គិតទៅ ២នាក់ ហ្នឹងទៅបាត់ ប៉ុន្តែគាត់ថា គាត់ហ្នឹងចង់ដែរ ដល់ដឹងដំណឹងមុន គេហៅគាត់ទៅឱ្យប អ៊ុក វិធុន ហ្នឹងគេធ្វើសច្ចាស្បថស្បែអីអញ្ចឹងទៅ សរុបសេចក្តីមកពួកនោះក្នុងរយៈពេល ៣អាទិត្យ ៥អាទិត្យទៀតអត់ទាន់មកទេ ។ ប៉ុន្តែបើសិនណា ថាចេញពីបងទៅវិញថាទេ ខ្ញុំអារឿងចរចាអត់អីទេ ខ្ញុំសុខចិត្ត ចរចាមើល មើលលោកចង់និយាយពីរឿងអី ? ខ្ញុំចង់ដឹងដែរពីរឿងបញ្ហាអី ឬលោកចង់អញ្ជើញមកមើល ហើយចេញទៅវិញទៅ ២-៣ថ្ងៃ ក៏អត់អីដែរ អញ្ជើញមកចុះ ពីព្រោះពួកនោះវានឹកស្រុកនឹកភូមិវាដែរ ។ អានោះគឺថាជាគោលជាគំនិតមួយដែរ ប៉ុន្តែបើសិនណាជាវាចេញពីយើងទៅវិញគឺអត់អីទេ ហើយរឿងបញ្ហា មានបញ្ហាពីព្រោះវាអាងវាមានឧត្តមសេនីយ៍៣នាក់យ៉ាងម៉េចៗថាបងឱ្យកំទេចចោលនោះណា គឺថាបងលែងគេមិនព្រមឱ្យទៅតាមច្បាប់តាមអីៗហ្នឹងដល់ពេលនេះយើងទៅការពារអាពួកនេះមក ខ្ញុំថាចុះបើដាក់គុក ១ខែ ២ខែអីល្អ ស្រាប់តែវាដេរមួយមាត់ថា អីចាប់អ្នកណាមួយដាក់គុកអញ្ចឹងហ្មា?... ទាំងអស់គ្នាហ្នឹង បើសិនគេកោះហ្នឹង អញ្ចឹងបើយើងឈរលើជំហរត្រឹមត្រូវ អាហ្នឹងគួរៗតែគិតមើល ពីព្រោះដូចជារឿងបញ្ហាច្បាប់ដែលគេទាមទាររឿងបញ្ហាដែលចាំឱ្យជុំគ្នា មកចាំឱ្យឡូហ្សីក ព្រោះអាហ្នឹងមក ពួកហ្នុងមកក៏គ្មានអីខុសពីកម្មវិធីសព្វថ្ងៃដែរ ខ្ញុំថាចង់ជួបសម្តេច ជា ស៊ីម តែលោកថា ឱ្យជួបថ្ងៃច័ន្ទ ចង់ជំរាបជូនលោកថា កុំឱ្យចង់យកថ្ងៃទី ២៨, មកដល់ថ្ងៃហ្នឹង ជូនកាលវាអត់មកទេ........។

**សម្តេច** : ខ្ញុំគាំទ្រថ្ងៃទី២៨ ហ្នឹង ជាឱសានវាទ មិនគួរទេ ។ បញ្ហាខ្ញុំគិតថាប្រហែលជានៅនោះវាខ្វះព័ត៌មាន អារឿងបញ្ហាមក យើងរហូតដល់ទៅស្នើអគ្គលេខាអង្គការសហប្រជាជាតិ ដើម្បីឱ្យគេជួយនាំបងប្អូនត្រឡប់មកវិញ ។ គ្រាន់តែថាព័ត៌មាននៅបាងកកដូចជាត្រូវបានបំភ្លៃខ្លាំងជាងនៅ បំភ្លៃហើយបំភ័យ មិន សារឿន និង ឃុន ភីណុប អីហ្នឹង ទាក់ទងតាមកាណាល់ក្រោយ ដើម្បីត្រឡប់មកវិញ ។ អារឿងវាអញ្ចេះ ឥឡូវយើងពិនិត្យមើលការពិតរឿងសម្តេចក្រុមព្រះហ្នឹង ខ្ញុំគិថ្ងៃទី១៥ ខែ៧ ប្រជុំនៅហ្នឹង ថ្ងៃហ្នុងថាបង ជា ស៊ីម គាត់មកដែរ ប៉ុន្តែដោយសារតែចុងក្រោយ គាត់គិតថាគាត់ជាប្រមុខរដ្ឋស្តីទីពុំគួរចូលពាក់ព័ន្ធទេ ។ ខ្ញុំ ឯកឧត្តម ស ខេង, ឯកឧត្តម សាយ ឈុំ, ឯកឧត្តម អ៊ឹង ហួត, ឯកឧត្តម ឡូយ ស៊ីមឈាង, ទន់ ចាយ, អ៊ូង ផន ជួបគ្នានៅហ្នឹង ។ ខ្ញុំថារឿងសម្តេចក្រុមព្រះយើងទុកចិត្តសិនទៅ កុំអាលអី កុំអាលធ្វើបញ្ហាហ្នឹង ព្រោះបញ្ហានេះគឺយើងធ្វើដូចមិនដឹងមិនឮទៅ អញ្ចឹងក៏ អាហ្នឹងជាគំនិតខ្ញុំអូសបន្លាយ។ ប៉ុន្តែសម្តេចក្រុមព្រះលោកទៅជ្រុលហួស ដូចជាកាលគេដកទូត ដកអគ្គរដ្ឋទូតវិលចូលស្រុក វាមិនមែនរឿងទើបតែសំរេចថ្ងៃហ្នឹង រួមមានទាំងការសំរេចរបស់សម្តេចក្រុមព្រះខ្លួនឯងដែរតើ ដូចជា សេរីវត្ត ដូចជាស្អី១អ្នកដែលអស់អាណត្តិត្រូវមកក្នុងស្រុកហ្នឹង សម្តេចក្រុមព្រះខ្លួនឯងហ្នឹងលោកស៊ីញេ រួចអានេះដល់ដំណាក់កាលដែលគេហៅទូតចូលស្រុកណាំ លោកទៅសរសេរសំបុត្រមួយទៅ កូហ្វី អាណាន់ ដើម្បីនឹងបដិសេធចោលនូវព្រះរាជក្រឹត្យរបស់ប្រមុខរដ្ឋស្តីទីដែលមានការប្រទានសិទ្ធិរបស់ព្រះមហាក្សត្រ ដល់អញ្ចឹងបានជាកក្រើកនៅភ្នំពេញនេះធម្មនុញ្ញនេះ បើយើងអត់អោន បើយើងអត់អោនវាទៅចូលដល់អាចំណុចមួយនៃការ ដែលធ្វើ អាដែងនែ៎ ធ្វើជាការវាយលុកលើទិដ្ឋភាពនយោបាយ និងផ្លូវច្បាប់មកលើយើងវិញ ។ អញ្ចឹងបានជាសភាត្រូវរុញដកអភ័យឯកសិទ្ធិ ដើម្បីបញ្ជូនសំណុំរឿងទៅតុលាការ ។ ប៉ុន្តែហើយរឿងទាក់ទិនជាមួយនឹង ជាមួយនឹងបញ្ហា ហេតុអី រឿងនេះវាអញ្ចេះ តាមខ្ញុំអារឿងគាត់ គេហៅត្រូវការហ្នឹង ព្រោះគាត់ធ្វើកិច្ចការងារហ្នឹងមិនអស់រឿងរបស់គាត់ ហើយព័ត៌មានរបស់យើងទៅជាមួយគាត់ហ្នឹងក៏យើងឃើញថាបងប្អូនក៏វាមិនគ្រប់ ។ ការជាក់ស្តែងគឺរដ្ឋាភិបាលរក្សាកន្លែងនេះទាំងអស់ អញ្ចឹងបានជាខ្ញុំមានចេញសេចក្តីសំរេចលប់ចោលនូវសេចក្តីសំរេចរបស់ថ្នាក់រដ្ឋមន្ត្រីខ្លះ ដូចជារដ្ឋមន្ត្រីក្រសួងសាធារណការ គាត់ចេញសេចក្តីសំរេចតែងតាំងអ្នកនេះអ្នកនោះ ជំនួសបងប្អូនដែលចាកចេញណាំ ខ្ញុំសុខចិត្តប្រកាសលប់ចោល ឥឡូវនេះមកវិញទៅ យើងរក្សាប៉ុស្តិ៍ឱ្យបងប្អូនទាំងអស់។ ព្រោះរឿងផ្ទុះអាវុធវាកើតឡើងតែ ទី១បទសម្ភាសន៍របស់សម្តេចក្រុមព្រះ ព្រឹកថ្ងៃទី៥ ព្រលឹមអុលឡើងមិនទាន់បានអីផងខ្ញុំមិនទាំងដឹងរឿងផង ចេញបទបញ្ជា បទបញ្ជាហើយ ដែលជាបទបញ្ជាចាប់ផ្តើមមានការបើកប្រយុទ្ធផ្ទុះអាវុធ ។ យើងសុំឱ្យដក់តែបទបញ្ជាហ្នឹងចេញទេ ទី២ការតែងតាំងនាយឧត្តមសេនាធិការនាយឧត្តមសេនាធិការរង តាមផ្លូវច្បាប់ណាំ អារឿងហ្នឹងវាជារឿងដែលទាក់ទិនជាមួយនឹងព្រះរាជក្រឹត្យលោកអត់មានសិទ្ធិតែងតាំងនាយឧត្តមសេនាធិការទេ រដ្ឋាភិបាលគេនៅនេះ សភាគេនៅនេះ ព្រះមហាក្សត្រនៅនេះ ចង់តែងតាំងអញ្ចឹងវាឆ្លងអាហ្នឹង អញ្ចឹងថ្ងៃទី២ ខែ៨នេះ គឺយើងបាននិយាយបានបញ្ជូននូវអនុស្សរណៈមួយទៅតាមពួក អាស៊ានយើងហ្នឹងនេះ ថាត្រូវដកចេញនូវអា២ចំនុចនេះទៅ ហើយខាងរដ្ឋាភិបាលដោះដូរត្រឡប់មកវិញធ្វើអី គឺឱ្យបងប្អូននេះត្រឡប់មកវិញកាន់ប៉ុស្តិ៍ដែលរក្សា

ហ៊ានៈតួនាទីដដែលហ៊ានៈតួនាទីដដែលទាំងអស់។ អញ្ចឹងបានសេចក្តីថាទ្វារមានបិទឯណា អត់មានបិទអីទាល់តែសោះ ប៉ុន្តែអាហ្នឹងវាជាប្រសិទ្ធិភាពមួយ មិញហ្នឹងនែ៎ ស្រី មណ្ឌល ទើបតែចេញពីខ្ញុំទៅមិញ គឺថាគ្រាន់តែអាវុធនៅផ្ទះ ស្រី មណ្ឌល ស្រី មណ្ឌល មិនដឹងជាប់គុកប៉ុន្តែយើងត្រូវដឹងថា យើងអរ-គុណគេវិញ ឥឡូវនេះដល់យើងសរុបអាវុធទៅជាង ១ម៉ឺនដើម អាំប្រ៉ាស់ ជាង៣០០ ។ ខ្ញុំមិនដែលឃើញសង្គ្រាមណា ឬក៏ប្រទេសណាដែលមានប្រព័ន្ធអាវុធដែលវាទំនើបដូចនៅទីក្រុងភ្នំពេញទេ តាំទ្រពាក់កណ្តាល ដែលហៅថាប្រភេទតាំទ្រ យើងមិនប្រើប្រភេទអាវុធវាយលុកអាកាទេ ប៉ុន្តែចាប់ពីអែរ៉េប៉េដេទៅ B40, B41, DK75, 82mm ស្អី។ហ្នឹង អាហ្នឹងសុទ្ធតែចូលអាំប្រ៉ាស់អីហ្នឹងអាហ្នឹងរដ្ឋាភិបាលដែលកុំម៉ង់ទិញឯណា ? បាញ់រ៉ថក្រោះអង្គរក្សខ្ញុំដែលទៅផ្ទុបនៅមុខសកលវិទ្យាល័យអាលាយរថក្រោះ អាហ្នឹង M86 បាញ់។ អញ្ចឹងឯកសារនេះ បើយើងឃើញទិដ្ឋភាពបែបនេះ គឺយើងបានដាក់ចេញអាហ្នឹងទៅហើយរក្សាគោលជំហរ ឥឡូវខ្ញុំនៅមិនឯកភាពជាមួយនឹងឱសានវាទនៅថ្ងៃទី២៨ ដកសមាជិកសភានេះ យើងកុំអវត្តមានតាមទំលាបធម្មតា អាហ្នឹងខ្ញុំឯកភាពលើចំណុចនេះ ។ ទំលាប់ធម្មតាអវត្តមានដោយគ្មានហេតុផល អាហ្នឹងរឿងមួយ តែបងប្អូនមួយចំនួនចាកចេញដោយការភ័យខ្លាច បើដោយការភ័យខ្លាចត្រូវទុកចន្លោះឱ្យបងប្អូនវិលត្រឡប់មកវិញ ។

**សុន ឆ័យ :** បាទ!

**សម្តេច** : អញ្ចឹងទេ អញ្ចឹងទុកត្រូវទុកអត់មានរយៈពេលឬក៏យ៉ាងម៉េច ? មានរយៈពេលដែរ ប៉ុន្តែយើងកុំអាលកំណត់អី យើងទុកពេលឱ្យតំណាងរាស្ត្រ..ទៅ ដែលអង្គការសហប្រជាជាតិ ដែលយើងស្នើគេណាំដើម្បីឱ្យគេទៅហៅបងប្អូនហ្នឹងមក យកមក មកមើលណាំ ហ្នឹងហើយយើងធ្វើ ធ្វើរបៀបហ្នឹង ។

**សុន ឆ័យ :** វុញបាល់ឱ្យគេវិញ ។

**សម្តេច** : វុញបាល់ឱ្យគេវិញ អញ្ចឹងបានជាខ្ញុំ ខ្ញុំអត់នេះទេ ខ្ញុំបានផ្តល់មតិ, ពិតមែនតែខ្ញុំមានការនិយាយខ្លះ ថាក្រែងលោមិនមកវិញអញ្ចឹងទៅ សភាគេដកចេញអីអញ្ចេះអញ្ចុះ ប៉ុន្តែជាផ្លូវក្នុងនេះខ្ញុំថាកុំ កុំវុញព្រោះអញ្ចេះ អញ្ចឹងបានខ្ញុំមិនយល់ព្រម ហើយរឿងនេះគឺជាជោគជ័យមួយនៅក្នុងដំណើរ។ មិនយល់ព្រមយ៉ាងម៉េច ? ព្រឹកភ្លាមលោក គៀង វ៉ាង ឯកឧត្តម យូ ហុកគ្រី និង យ៉េង ម៉ារ៉ានី គាត់ចាប់ផ្តើមលេងមួយបន្ទុះ ប្រវែងណេះហ្នង ខ្ញុំទូរស័ព្ទទៅឯកឧត្តម ស ខេង ភ្លាមសំរួល ខ្ញុំថាខេង អើយកុំឱ្យសោះ បើសិនជាគ្នាទើបតែទៅបានពាជំហានដោយសារការភ័យខ្លាច ដល់តែយើងតែងតាំងមនុស្សជំនួសគ្នាទៅកាន់តែឆ្ងាយ ហើយពេលហ្នុងភ្លាមគឺត្រូវតែងតាំង ស្រី មណ្ឌល ពីស្វាយរៀងឱ្យទៅខេត្តកំពង់ចាមជំនួស កង សារិន ។ ខ្ញុំថាមិនបានទេ ខ្ញុំទប់ដល់ឥឡូវមានស្អី កង សារិន មកវិញ ត្រូវមកវិញ ទៅកាន់អនុខេត្ត ហើយអនុរដ្ឋលេខាធិការ ៤នាក់ ខ្ញុំប្រាប់ទៅសៀមរាបទាំងអស់គ្នា ខ្ញុំប្រាប់បង អ៊ឹង ហួត, បង ចាយ, បង ខែម ខ្ញុំថា បង! យកល្អបងឯងទុកកន្លែងហ្នឹងឱ្យចន្លោះសិនទៅ វាអត់មានខាតបង់អីទេ បងជឿខ្ញុំទៅ គាត់ ថាទេ! ឥឡូវត្រូវដាក់ខ្ញុំក៏ព្រមតែងតាំងទៅអនុរដ្ឋលេខាធិការក្រសួងសុខាភិបាលមួយ, ពាណិជ្ជកម្មមួយ, ផែនការមួយ, ហើយនិងប្រៃសនីយ៍មួយ ៤នាក់ហ្នឹង ។ ដល់តែងតាំងបានប៉ុន្មានថ្ងៃ ៤នាក់ហ្នឹងគេមកដល់វិញ

ឥឡូវយើងគិតថាម៉េច ? បើយើងមិនឱ្យគ្នាចូលធ្វើការវាអត់កើត អញ្ចឹងត្រូវតែងតាំងបន្ថែម។ ខ្ញុំគិតថាបើសិនជាព័ត៌មាននេះបានទៅដល់បងប្អូននោះពិតប្រាកដ ខ្ញុំជឿថាបងប្អូននោះមិនមែនសុខចិត្តដេកព្រៃទេ អញ្ចឹងបានជាឥឡូវនេះយើងប្រើកាណាល់ច្រើនបន្តិច ព្រោះសូម្បីតែនេះ ឥឡូវបានជំនួយការឯកឧត្តម ឡូយ ស៊ីមឈាង និងជំនួយការ ហូ សុខ ជិះយន្តហោះមកជាមួយខ្ញុំថ្ងៃនេះ ផ្កាយពីរដែរណាំ ហើយទៅនៅបាងកកហ្នុងដែរ ថ្ងៃហ្នុងថាបងប្អូនមួយចំនួនត្រៀមមកហើយ ប៉ុន្តែពួរថក្រោះសម្តេច ជា ស៊ីម និង រថក្រោះសម្តេច ហ៊ុន សែន កំពុងត្រៀមរៀគ្នានៅកណ្តាលភ្នំពេញ ។

**សុន ឆ័យ** : រាល់ថ្ងៃបងរាល់ថ្ងៃ អ្នកដែលយកព័ត៌មានច្រើនជាងគេ ជាពិសេស រង្សី, ប៉ោ ប៊ុនស្រី មួយដែលខ្ពស់ហ្នឹង អង្គុយជិតនៅក្នុងឡាននោះ គឺថាគេជិះឡានមកប៉ោយប៉ែត ។

**សម្តេច** : ហ្នឹងហើយ!

**សុន ឆ័យ** : នៅអារញ្ញនេះរាល់ថ្ងៃហ្នឹង យកទាំងជុំៗ ព័ត៌មានតាមកាសែត ពួកអាហ្នឹងចេះតែថា ប៉ុន្មានលានៗអីទៅណាំ អូ! ជិតហើយៗ មិនអីទេ ជិតដល់ពេលយើងហើយបន្តិចទៀត យើងទៅតែម្តងអញ្ចឹងណាំរាល់ថ្ងៃ ជាពិសេសទៅឱ្យចៅហ្វាយស្រីគេតែម្តងយកទៅផ្សព្វផ្សាយនៅហ្នឹង និង១ក្រុម មានអាក្រុមជួនអីមិនដឹងមកពីណាទេ មានស្រីមានអីនៅហ្នឹង ពួក រង្សី វាធ្វើ ធ្វើអារឿងបញ្ហាថា CPP តែងតាំងឯណា រង្សី នេះអញ្ចឹងណាំ អញ្ចឹងបានថាវាពិបាកណាស់ ពីព្រោះវា ប៉ុន្តែវានឹងធុញហើយឥឡូវវាចាប់ធុញហើយ អាថ្ងៃគេ រឿងនៅចាក់អង្រែនោះណាំ....... ខ្ញុំថាដេកយោលអង្រឹងទៅតង់តែថ្ងៃណាដាច់ខ្សែអង្រឹងទេ ។

**សម្តេច** : ប៉ុន្តែតាមខ្ញុំ ខ្ញុំថាទុកពេលទុកដោយគ្មានការកំណត់ ។ ខ្ញុំបានពិភាក្សាជាមួយបងប្អូនខាងយោធា និងខាងសន្តិសុខ ខ្ញុំថារក្សាទុកទៅមិនចាំបាច់មានកំណត់ពេលទេ ខាងផ្នែកយោធា ដោយឡែកសភាយើងមិនមានសិទ្ធិអីពិភាក្សាទេ ប៉ុន្តែតាមយោបល់ខ្ញុំគួរកុំឱ្យមានប្រាកចាកសមាជិកភាព នេះមិនមែនរឿងធម្មតាទេ ប៉ុន្តែរឿងធំមួយទៀត... ដោយសាររឿងអី ខ្មែរក្រហមយើងម៉េចទទួលបាន ចុះបងប្អូននេះទទួលម៉េចមិនបាន អ្នកដែលមានកំហុសតែប៉ុន្មាននាក់តើ យើងចោទប្រកាន់តែប៉ុន្មាននាក់ទៅបានហើយ ហើយរឿងនេះ រឿងទាក់ទិននឹងនេះ យើងត្រូវធ្វើការស៊ើបអង្កេត ព្រោះឥឡូវការស៊ើបអង្កេតនៅទីនេះ ខ្ញុំសូមជំរាបថា ខ្ញុំមិនអាចមិនយោគយល់ឱ្យអ្នកណាមួយរួចខ្លួនទេ ព្រោះរឿងនេះវាអើយ ឆ័យអើយឆ័យ គ្មានពីណាក្នុងមួយជាតិនេះដូចគ្មាននរណាពិបាកជាងខ្ញុំទេ ។ ឥឡូវហ្នឹងឆ័យ ឯងមើលសភាពការណ៍កើតឡើងចំពេលដែល FCP ចែកជាពីរ ដល់ក្រោយសភាពការណ៍ FCP មួយថាគាត់ឈ្នះ អញ្ចឹងគាត់ទៅបំភ័យ FCP មួយទៀតមិនងាប់ឯខ្ញុំ ។ B.L.D.P ក៏បំបែកជាពីរអញ្ចឹង B.L.D.P ម្ខាងនោះគាត់ថាឈ្នះ ម្ខាងថានេះអញ្ចឹងទៅ ។ អញ្ចឹងរឿង រួចអាមនុស្សរបស់ CPP មួយចំនួន វាដូចថាវាឈ្នះ ជាអ្នកឈ្នះ ហ្នឹងដែលវាងាប់យើងអាខាងលើឯណោះ ។ ប៉ុន្តែដល់ពេលល្អត្រង់ថា ខាងគណៈកម្មការសិទ្ធិមនុស្សខាង មជ្ឈមណ្ឌលសិទ្ធិមនុស្សនេះ គេក៏បានស្រាវជ្រាវរួច វាបំបាត់ចោលនូវអាពាក្យចរចាមអារាមដែលថា ស្លាប់មនុស្សមួយថ្ងៃរាប់សិបរាប់រយនាក់នោះណាំ ។ ខ្ញុំកំពុងតែគាល់ព្រះករុណានៅឯប៉េកាំងទាំងអស់គ្នាហ្នឹង ស្រាប់តែកំពុងតែបាយ ហ្វាក់ពី

ទីកន្លែងណាមួយទៅថា រដ្ឋាភិបាលកំពុងតែដុតមនុស្សទាំងរស់នៅគីរីរម្យ៤០នាក់ ។ ដល់អញ្ចឹង អត្តមហេសីលោកមានបន្ទូលដែរ ប៉ុន្តែខ្ញុំ រួចហើយថា យី! អង្គរក្សសម្តេចក្រុមព្រះ ទាំង សួង ទាំង និត អីហ្នឹងត្រូវគេខ្វេះភ្នែកផង គេអីផង ហើយពេលនោះវាល្អត្រង់ថាអា និត វាទៅជាមួយ អ៊ុំង ហួត ឧត្តមសេនីយ៍ត្រីម្នាក់ដែលជាមេបញ្ជាការទៅជាមួយនឹងគ្នាហ្នឹង ដល់អញ្ចឹង ប៉ុន្តែរឿងនេះអ្វីដែល ស្តាយបំផុតគឺករណី ហូ សុខ ពេលហ្នុង ឯកឧត្តម ស ខេង គាត់រាយការណ៍ឱ្យខ្ញុំថា ហូ សុខ នៅក្នុងទូតសាំងហ្គាពួរ រួចហើយគឺឥឡូវគាត់ឱ្យមនុស្សទៅជួបជាមួយទូតសាំងហ្គាពួរហើយ អញ្ចឹងបន្ត ធ្វើកិច្ចការងារហ្នឹងទៅ អាពេលហ្នុងខ្ញុំកំពុងដោះស្រាយបញ្ហាអាណាធិបតេយ្យ អាក្រោយមួយថ្ងៃមិន មានចាប់ផ្តើមលួចប្លន់អីនៅក្នុងក្រុង ដល់ទៅប្រហែលជាកន្លះម៉ោងក្រោយ ឯកឧត្តម ស ខេង គាត់ក៏ រាយការណ៍ម្តងទៀតថា ឯកឧត្តម ហូ សុខ បានយកមកដល់ក្រសួងមហាផ្ទៃហើយ ខ្ញុំថាបើអញ្ចឹងត្រូវ រៀបចំបែបបទសំណុំរឿងតុលាការអីឱ្យបានច្បាស់លាស់ត្រូវមានព្រះរាជអាជ្ញា នៅក្នុងការចាប់ខ្លួនចាប់ អីនេះត្រូវឱ្យមានគ្រប់គ្រាន់ ស្រាប់ប្រហែល៥នាទីក្រោយឯកឧត្តម ស ខេង រាយការណ៍មកទៀតថា គេបាញ់ស្លាប់ហើយ ខ្ញុំថាវាហួសចិត្តតែម្តង មានអាព្រឹត្តិការណ៍ចង្រៃហ្នឹងមួយដែលធ្វើឱ្យខូចមុខមាត់ ដល់យើង ។ ប៉ុន្តែឥឡូវ ឧត្តមសេនីយ៍ពានាក់នោះ សួរថាគ្នាមានជាប់រឿងអី ទទេរស្អាតតែម្តង ប៉ុន្តែ គ្រាន់ថាមនុស្សហ្នឹងឡើងទៅស្លាប់ ទី១គឺថាឧត្តមសេនីយ៍ម្នាក់ស្លាប់ក្នុងរង្វង់ដែលគេហៅថា ដូចសមត្ថ-កិច្ចរបស់ខ្លួន ព្រោះគាត់ជាប្រធាននាយកដ្ឋានព្រហ្មទណ្ឌ វាមាននៅឯហ្នុងឯណា អាពេលមានការណ៍ ហ្នឹង វាអត់ទាំងដឹងរឿងអីគេ វាច្របូកច្របល់នឹងគេ វាមានបានប្រយុទ្ធបានអីនឹងគេឯណាគ្នានោះ ។ ពីរនាក់ទៀតគ្រាន់តែទៅ ស្លាប់នៅក្នុងប៉ុយប៉ែតគ្នារឿង គ្នាមាននៅហ្នុងឯណា ។ អញ្ចឹងទេយើងព្យួរជើង ប្រមាណ៣ខែក្រោយ ហើយរបាយការណ៍គណៈកម្មការមក ប៉ុន្តែយើងមិនមែនបញ្ចប់ការស្រាវជ្រាវទេ យើងនៅស្រាវជ្រាវតទៅទៀត ។ ឥឡូវយើងឃើញថាគ្រប់ករណីយើងអាច... ព្រោះធម្មតាតែបាញ់គ្នា ហើយគេមិនដែលមានរឿងល្អទេ ព្រោះកងទ័ពរដ្ឋាភិបាលអស់ជាង៣០នាក់ ប្រជាជនជាង៧០នាក់ រួចហើយបន្ទាប់ទៅ យើងនឹងត្រូវបែងចែកប្រភេទអ្នកដែលកប់ ហើយល្អបំផុតដែលយើងរកឃើញ .......។ ឥឡូវ ឆ័យ ឯងចង់បានមើល Tape ពីរទេ ? Tape ពីរនេះបានសន្និដ្ឋាន ហើយ Tape នេះ មិនមែននេះទេ ។

**សុន ឆ័យ**: អាហ្នឹងលើកពីរឿង លី ធុច លី អីអាហ្នឹង លីគេនិយាយដែរ ។

**សម្តេច** : ហ្នឹងណាំ ហ្នឹងហើយ Tape ទាំងពីរនេះ ក្នុង Tape មួយ ដែលថតនៅក្នុងបន្ទាយតាំងក្រសាំង មានចង់បងប្អូន៤នាក់ ឥឡូវយើងរកឃើញតែមួយទេ នៅបាត់៣នាក់ ។ ប៉ុន្តែលោកជំទាវ ឡូយ ស៊ីមឈាង លោកជំទាវ អ៊ុំង ហួត ដែលគេយកទៅក្នុងបន្ទាយហ្នុងដែរ ហ្នឹងហើយដែលយើងត្រូវ រកផ្លូវ អញ្ចឹងបាន ប៉ោ ប៊ុនស្រី ភ័យណាស់...... ប៉ោ ប៊ុនស្រី គ្មានលទ្ធភាព....... ខ្ញុំថាបើធ្វើការ ស្រាវជ្រាវ គឺស្រាវជ្រាវទាល់តែចប់ អត់មានឱ្យអ្នកណាមួយរួចខ្លួនទេ ព្រោះអត់ទទួលបានទេ អាហ្នឹង ព្រោះជារឿងមួយដែលវាអត់មានអ្នកណាត្រួតត្រាសភាពការណ៍ហ្នឹងបានទេ ប៉ុន្តែស្លាប់ដោយចាប់គេ បានហើយយកទៅសំលាប់ គឺអត់ឱ្យរួចទេ កន្លែងហ្នឹង ប៉ុន្តែតែដាក់ការស៊ើបអង្កេតទៅលើរឿង

អញ្ចឹងមួយមិនមែន១ខែ, ២ខែ, ៣ខែទេ ព្រោះប្រកាសកោក១តាមវិទ្យុ ទូរទស្សន៍ អញ្ចឹងធ្វើឱ្យអ្នកដែលវារត់បាត់កាន់តែឆ្ងាយ។ ប៉ុន្តែអារឿងហ្នឹងស៊ើបអង្កេតលើកនេះយើងធ្វើអញ្ចេះ អាហ្នឹងគឺខ្ញុំបានប្រជុំជាមួយនឹងរដ្ឋាភិបាល តំណាងឱ្យតាមសង្កាត់ ពីព្រោះនៅនេះមានលើកាដូ អាដហុក ហើយនិងវិទ្យាស្ថានលោក នៅ កាស៊ី ស្អី១ហ្នឹងនេះមកជុំគ្នាទាំងអស់ យើងបង្កើត ការពារអញ្ចឹង ធ្វើម៉េចឱ្យឯករាជ្យ ហើយឱ្យសិទ្ធិអំណាចគណៈកម្មការហ្នឹង ដើម្បីបញ្ជូនរឿងនេះទៅកាន់តុលាការដោយផ្ទាល់ទើបអាចដោះស្រាយបានបញ្ហា យើងមានយន្តការអន្តរក្រសួងមួយ ប៉ុន្តែបើសិនយន្តការអន្តរក្រសួងសុទ្ធសាធ គឺទៅអត់រួចទេ ព្រោះរដ្ឋាភិបាលដដែល គេចាំមើលរដ្ឋាភិបាល រដ្ឋាភិបាលឱ្យមនុស្សទៅវាមិនបង្វាងគេ ខ្វះជំនឿទុកចិត្តហើយ ។ អញ្ចឹងទេ យើងទៅអង្គការសិទ្ធមនុស្សក្រៅរដ្ឋាភិបាលមកចូលរួមក្នុងគណៈកម្មការស៊ើបអង្កេតនេះឱ្យមកចូលហ្នុង ប៉ុន្តែក៏វាមានខាងអង្គការសិទ្ធិមនុស្សខ្លះថា គេបានចូលរួមក្នុងការធ្វើរបាយការណ៍ហ្នឹង អញ្ចឹងទេគេមកចូលរួមក្នុងការស៊ើបអង្កេតទៀតអត់កើត អញ្ចឹងទេយើងក៏ផ្តល់ឱ្យអង្គការហ្នឹងតាមឃ្លាំមើល។ ដូច្នេះ អានេះចាត់ការមុនពេលត្រូវទៅញ៉ូវយ៉ក ឥឡូវស្រាវជ្រាវបានករណីមួយចំនួន ហើយករណីមួយចំនួននៃការ ប៉ុន្តែមិនទាន់ចូលដល់អាជំរៅ អ្នកណាឃាតករស្អី១ រឿងវាទៅដល់ណាទេ ប៉ុន្តែករណីមួយចំនួនត្រូវបានស្រាវជ្រាវហើយ ។ អញ្ចឹងយើងមានយន្តការមួយ ដែលមានកំលាំងមានសមត្ថកិច្ចរបស់រដ្ឋាភិបាល ហើយចូលពាក់កណ្តាលដោយសមាជិកអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែមានអង្គការក្រៅរដ្ឋាភិបាលមួយទៀតបូកជាមួយ U.N Center ហ្នឹង គឺថាធ្វើការឃ្លាំមើល លុះត្រាតែអ្នកឯងធ្វើអញ្ចឹងក្នុងប៉ុន្មានករណីនេះ។ ព្រោះអារឿងនេះ ខ្ញុំគិតថាការចាត់ការនៅទីនេះ វាដូចជាអ្នកដែលគេតាមដានជាប់ព្រឹត្តិការណ៍នៅទីនេះ គេមានការកក់ក្តៅក្នុងចិត្តមួយផ្នែកដែរ ។ ប៉ុន្តែអ្វីដែលវាពិបាកដល់យើងនៅត្រង់អញ្ចេះ ត្រង់ថាព័ត៌មានយើង ដែលយើងចាត់ការវាទៅអត់បានដល់បងប្អូន អត់ទៅដល់គេឯង ១២អាទិត្យទៅទៀតប៉ុណ្ណឹង ប៉ុន្តែខ្ញុំយល់ថាសភាពការណ៍នេះមិនយូរទេ វារលត់រំងាប់ ។

**សុន ឆំយ:** វាអញ្ចេះក៏ស្រួលដែរ ពេលខ្ញុំគ្រាន់តែមកដល់ភ្នាម ព្រោះខ្ញុំមកមានការទាក់ទងតាមរយៈ ស៊ុន ឆាយា ខ្ញុំឱ្យអង្គការ U.N ខាងសិទ្ធិមនុស្សនោះប្រាប់គេ ហើយខ្ញុំប្រាប់ទូតប្រាប់អីអញ្ចឹងទៅគេជូនទៅចូលទូតទៅ Register នៅទូតអូស្ត្រាលីអីទៅជួបជាមួយគេវិញ ។ ប៉ុន្តែពួកអេគឺបក្រោយនេះខ្លាំងជាងគេ អា President ហ្នឹងហ្នង អា President ហ្នឹង មេ១អី១ហ្នឹងណាំ ។ បើតាមខ្ញុំដឹងណាំ តាមមើលគាត់ទៅបាត់ហើយ គាត់អត់ហ៊ាននៅទេ ប៉ុន្តែមុនខ្ញុំប្រាប់គេដូចស្រួលទេ ជជែកមើលទៅណាំ មើលទៅគាត់មកមិនមែនរបៀបមកប្រឆាំងទេ គឺនៅកណ្តាលពួកនៅក្នុងអង្គការសិទ្ធិមនុស្ស។

**សម្តេច** : អត់អីទេ ពួកហ្នឹងថ្ងៃមុនមកពិភាក្សាគ្នាស្រួល ព្រោះជារួមរបាយការណ៍របស់គាត់ផ្តល់ចំណុចវិជ្ជមានឱ្យយើង២យ៉ាង វិជ្ជមាន ទី១ អាពាក្យចចាមអារ៉ាមថាកាប់សំលាប់មនុស្សវាច្រើនបើប្រៀបធៀបទៅនឹងអ្វីដែលជារបាយការណ៍វារាប់រយរាប់ពាន់ ។ ចំណុចទី២ វាបានមូលដ្ឋានឱ្យយើងធ្វើការស្រាវជ្រាវការពិតណាស់ អញ្ចឹងបាននៅនេះគឺមានការស្ងប់ចិត្តមួយ ត្រង់អញ្ចេះ ត្រង់ថាចាប់ផ្តើមក្រោយសភាពការណ៍ហ្នឹង ប៉ុន្មានថ្ងៃយើងបានហៅរកគេ ហើយសូមឱ្យគេជួយសហការ គេមានបំណងទៅ

ទីណា យើងឱ្យគេទៅទីហ្នឹង កាកបាទក្រហមមក ខ្ញុំសរសេរសំបុត្រថាគ្រប់កន្លែងទាំងអស់ឱ្យទៅ ដោយគ្មានការហាមឃាត់ ។ ដល់អញ្ចឹងគេទៅមើលឃើញការជាក់ស្តែងអញ្ចឹងទៅ គឺថា វាបង្កើត នូវបរិយាកាសមួយមានការសហការគ្នា ហើយលោក ហាំម៉ាប៊ែក មកក៏យើងបានទទួលយកអាហ្នឹងថា ដំបូងខ្ញុំគិតថា សំរេចដាក់ឃុំមនុស្សមួយចំនួនដែរ ដែលវាមានដូចជាឧត្តមសេនីយ៍អីអញ្ចឹង ដែល ពាក់ព័ន្ធនៅក្នុង ដូចថានៅក្នុងអាក្រឹបខ័ណ្ឌគេហៅថា ការទទួល ទទួលយ៉ាងហោចណាស់អ្នកឯង ទទួលខុសត្រូវរឿងហ្នឹង ប៉ុន្តែដល់ទៅមើលអាច្បាប់ អាលក្ខន្តិកៈអាត្រូវដាក់ឃុំ វាកើតអារឿង មួយចន្លោះទៅទៀត អញ្ចឹងយើងក៏ថា ប៉ុន្តែត្រូវធ្វើអញ្ចេះ ការស៊ើបអង្កេតមួយនៅទីនេះ ការដោះ លែង មែនថាតែដោះលែងទេ បានសេចក្តីថាពីកាលដែលនេះយើងក៏មិនមែនចាប់ខ្លួនគេទេ យើងគ្រាន់ តែព្យួរការងារតើ៎ យើងព្យួរការងារដើម្បីយើងយកពេលស៊ើបអង្កេត ក្នុងដំណើរការស៊ើបអង្កេតនេះ គឺយើងអោយបងប្អូន FCP នៅទីនេះធ្វើជាប្រធានទៀត ។ អារបាយការណ៍អត់ចេញ ចេញ សាច់ការអីបាន យើងព្យួរការងារតទៅទៀតក៏អត់បានការអីដែរ សំរាប់មនុស្សពាក់នោះ វាអត់ មានពាក់ព័ន្ធណា អាអ្នកដែដល់វាផ្សេង តែដល់ពេលយើងដោះនេះទៅ យើងចាប់ផ្តើមរុញការស្រាវ ជ្រាវតាមអារូបមន្តចារកម្ម ជូនកាលវាផ្ទុះ ផ្ទុះហើយបែកចេញ អញ្ចឹងយើងរកឃើញបានតែ២-៣ ករណី យើងអាចដោះស្រាយបានបញ្ហាច្រើន ដោះស្រាយបានបញ្ហាច្រើន អាហ្នឹងខ្ញុំធ្វើខ្ញុំនៅ... ព្រោះនេះរឿង ឆ័យ អើយ! អញ្ចឹងបានខ្ញុំមានពេលខ្លះខ្ញុំចង់ថ្វាយបង្គំ ខ្ញុំអរគុណជាមួយអ្នកតំណាងរាស្ត្រ ខ្លះ យើងនឹង ខ្ញុំចង់ថ្វាយបង្គំ ព្រោះបញ្ហាបើសិនបណ្តោយឱ្យដូចអតីត **ឃ្សូរះអឿ** បណ្តោយឱ្យដូច **សេរ៉ាលីអូន** គ្រោះថ្នាក់ណាស់ៗ។ ប៉ុន្តែនេះយើងក៏រិតបានប៉ុណ្ណឹង អញ្ចឹងបានខ្ញុំនិយាយដោយត្រង់រឿង ហ្នឹង ខ្ញុំមិនសប្បាយចិត្តជាមួយបងប្អូនមួយចំនួននៅក្រុមតា ចាយ ការដែលមិនសប្បាយចិត្តរបស់ខ្ញុំ គឺនៅ ត្រង់ថា ខ្ញុំថាឥឡូវធ្វើយ៉ាងម៉េចដើម្បីកុំឱ្យបងប្អូនភ័យខ្លាច តែនៅតីនេះវាកើតមានបញ្ហាជំងឺ អញ្ចេះ ជំងឺបំភ័យឱ្យគេរត់ដើម្បីយកទ្រព្យគេ រឿងវាអន្តរាយត្រង់ហ្នឹង រួចហើយវាចាប់ផ្តើមមានបញ្ហា ឆ័យ ឯងជួបបង បង ស៊ូ ជី បង ស៊ូ ជី មកបាយនៅហ្នឹង អ្នកតំណាងរាស្ត្រប៉ុន្មាននាក់មកបាយហ្នឹង គាត់ថាសម្តេច គេមកឱ្យខ្ញុំ បំភ័យឱ្យខ្ញុំទិញសំបុត្រយន្តហោះឡើងទៅ សម្តេចទី២មកកាប់ចោល ប៉ុន្តែខ្ញុំយល់សម្តេចទី២ ដូចមិនដល់ប៉ុណ្ណឹង។ មើលទៅបំភ័យឱ្យគាត់ទិញសំបុត្រយន្តហោះបង ស៊ុត ប៉េងគន់ គាត់នៅចំប្រឡោះហ្នុង ហើយតំបន់ហ្នុងនៅល្ងាចថ្ងៃទី៥ហ្នុង គេបាញ់ទីតាំងតាំងក្រសាំងដែល គ្រាប់ផ្លោងធ្លាក់ដំបូង វៃពីតាំងក្រសាំងមកធ្លាក់តំបន់គាត់ហ្នឹង ដល់អញ្ចឹងគឺ បងប្អូននៅតំបន់ហ្នឹងថាឱ្យ ចេញ ចេញ គាត់ទៅត្រឹមកំពង់ឆ្នាំងទេ ។ ដល់ទៅត្រឹមកំពង់ឆ្នាំង ស្រាប់តែក្រោយព្រឹត្តិការណ៍ហ្នឹង បានប៉ុន្មានថ្ងៃឮបងប្អូន FCP តា ចាយ ហ្នឹងថានែ៎! គេចាប់បានអ្នកតំណាងរាស្ត្រក្បាលរឹង ។ ស្រាប់តាហ្នឹងប្រុយតែម្តង ប្រុយធ្លាក់ទៅដល់បន្ទាយមានជ័យ ដល់តែទៅដល់បន្ទាយមានជ័យ ខ្ញុំបានបង ឡាយ ខែក, ឯកឧត្តម អៀង ម៉ូលី និងបង យ៉ុន ខ្ញុំថាបងទៅមើលមើល៎ ខាងហ្នុងឃើញបងប្អូនហ្នឹង អញ្ជើញហៅប្រមូលត្រឡប់មកវិញមក ពេលគាត់ទៅក៏យកបាន ជួប២នាក់ ជួបបង ស៊ុត ប៉េងគន់ និងបង ថោង នៅ ស្រាប់តែបង ថោង នៅ អ្នកណារត់ទៅពីណេះទៅបំភ័យគាត់រត់ធ្លាក់ទៅដល់សំរោង ហើយ ឡើងទៅបាងកកបានចុះមក ខ្ញុំឱ្យឧទ្ធម្ភាគចក្រទៅយកតាមកោះកុង បង ថោង នៅ គាត់រត់បានឆ្ងាយ ជាងគេ ។ ឯបង ស៊ុត ប៉េងគន់ គាត់មកថា អ្ហេ! រឿងធំ រឿងហ្នឹង ហើយបង ណុប លាន មើល៎!

តំណាងរាស្ត្រខេត្តតាកែវរបស់ FCP មានបង ណុប លាន, បង គុយ ម៉ែយ៉ារ៉ា, បង អ៊ិត សុគន់ ដល់ជួបខ្ញុំ ខ្ញុំថា អ្នកណាទៅគំរាមបងឯង ? ថាគ្នាឯងហ្នឹង FCP តាម ចាយ ខ្ញុំថាងាប់ហើយ បើអញ្ចឹងវាមិនងាប់ខ្ញុំ ហ្នឹងរឿងមួយទៅ ។ រឿងមួយទៀត បំភ័យគេឱ្យរត់ដើម្បីយកផ្ទះគេ អាហ្នឹងមានទាំង CPP មានទាំង FCP ។ ប៉ុន្តែយើងបានចេញសភាពការណ៍ហ្នឹង យើងចេះដោះទាន់ៗ ខ្ញុំកំពុងតែអង្គុយលេងនៅខ្ទះខាងមុខជាមួយអ្នកតំណាងរាស្ត្រប្រហែលជាជាង ១០នាក់ ហើយទទួលទូរស័ព្ទ ពីណាកំពុងទៅរើផ្ទះអ្នកតំណាងរាស្ត្រណាមួយ ខ្ញុំថាអស់ចិត្តតែម្តង ហើយណាមួយស្រាប់តែប្រពន្ធ គ្រួច យៀម មកដល់នេះយំស្រែកនៅនេះ ថាមានពីណាឡើងទេនៅផ្ទះគាត់ បានជាខ្ញុំដាក់កំណត់ ម៉ោង៨:០០ព្រឹកស្អែកត្រូវប្រពន្ធ គ្រួច យៀម ទៅនៅផ្ទះហ្នឹង រឿងប្តីរបស់គាត់ទៅទីណារឿងផ្សេង ប៉ុន្តែរឿងប្រពន្ធ ប្តីខុស.

**សុន ឆ័យ**: រឿងរបស់ប្តីទេ ។

**សម្តេច** : រឿងប្តី អញ្ចឹងបានថា ខ្ញុំប្រកាសហើយដរាប.

**សុន ឆ័យ**: ឥឡូវៗផ្ទះពីណាខ្លះដូចផ្ទះ ហូ សុខ ដូចអីឱ្យទៅគេវិញទៅកុំឱ្យពួកហ្នឹងទៅនៅ ឱ្យគេចេញទៅៗ ។

**សម្តេច** : ត្រូវតែចេញ ព្រោះអញ្ចេះដរាបណាតុលាការ មានតែតុលាការមួយគត់ដែលមានសិទ្ធិដកហូត អញ្ចឹងគឺផ្ទះមួយចំនួនដូចជាផ្ទះ ចៅ សម្បត្តិ, ផ្ទះ ញ៉ឹក ប៊ុនឆៃ, ផ្ទះ ហូ សុខ អីហ្នឹងគ្រាន់តែឱ្យចាំទេ ឱ្យចាំគ្រប់គ្រងបើមិនអញ្ចឹងទេរើរុះអស់ហើយ អត់មានឱ្យនរណាយកធ្វើជាកម្មសិទ្ធិទេ ។

**សុន ឆ័យ**: ថ្ងៃអង្គារ ខ្ញុំទៅពីព្រលឹមចេញទៅផ្ទះ ញ៉ឹក ប៊ុនឆៃ ខ្ញុំទៅឃើញអ្នកស្រុកមួយហ្វូងប្រហែល១០០នាក់ ខ្ញុំចូលទៅមើលទៅឃើញតា ឡៅ ម៉ុងហៃ ទៅដល់យំតែម្តង យី! ហ្នឹងតំណាងរាស្ត្រហើយមកពឹងខ្ញុំ ខ្ញុំដើរទៅមើលរួចពួកហ្នុងអត់ឱ្យគាត់ចូលទេ ខ្ញុំថាអត់បានទេ ពីព្រោះយើងផ្សាយថា ត្រូវការពារសន្តិសុខម្ល៉ោះ ខ្ញុំទូរស័ព្ទទៅ កែ គឹមយ៉ាន ភ្លាមខ្ញុំថាឯកឧត្តម បើឱ្យទៅគេនៅណា៎ ខូចឈ្មោះគណបក្សយើងអស់ហើយ ខ្ញុំក៏បង្គំថ្ងៃហ្នឹង ដាស់គាត់ឱ្យទៅដោះស្រាយរឿងហ្នឹង។ ប៉ុន្តែបងឯងចាំទេកាលទូរទស្សន៍មកសម្ភាសន៍ខ្ញុំណា៎ ខ្ញុំផ្តាំឱ្យពួកហ្នឹងណា៎ ឱ្យទៅជួបបងផង ថាឱ្យ ឡាយ ខែក ទៅទាក់ទងជាមួយនឹង ខូ ឈា ។ បងមានគេមកជំរាបទេ ? ព្រោះខ្ញុំភ័យណាស់រឿងហ្នឹង ព្រោះ ខូ ឈា វាបានសំលាប់ពួកហ្នឹង ឥឡូវវាបានចោទត្រង់ហ្នឹងច្រើនណាស់ ប៉ុន្តែបញ្ហាដែលដោះស្រាយមិនចេញប្រសិនណាបើអាចទៅបានត្រឹមណាឱ្យតែយើងយល់ដឹង ព្រោះវាមានសេនារិយោរបស់គេអញ្ចឹងណា៎ ត្រូវដោះទៅឱ្យម្ចាស់គេវិញ ។

**សម្តេច** : រឿងហ្នឹងកន្លងទៅខ្ញុំព្យាយាមឱ្យដោះស្រាយ យើងយកបានរថយន្តបានអីមកវិញបានមួយចំនួន ហើយនឹងផ្ទះនេះមិនចោទទេ ដូចជារបស់ករណីប្រពន្ធ ហូ សុខ ស្អីៗ ហើយអ្វីដែលខ្ញុំស្តាយបំផុតខ្ញុំស្តាយមនុស្សពានាក់ ស្តាយណាស់ រឿងនេះគឺខ្ញុំបញ្ជាជាបន្តបន្ទាប់ថាយ៉ាងណាក៏ដោយត្រូវខិតខំបំបែកបង គ្រួច យៀម, បង ម៉ែន ប៊ុនថន, បង លី សេងហុង ពានាក់ហ្នឹង ព្រោះមនុស្សនេះត្រូវគេចាប់បង្ខំទៅជាមួយទេ ជឿខ្ញុំចុះ គ្រួច យៀម គាត់មិនអាចប្រឆាំងជាមួយខ្ញុំទេ ព្រោះ គ្រួច យៀម គាត់ចូលគណបក្សប្រជាជនតាំងពីមុនបោះឆ្នោតឆ្នាំ១៩៩៣ ជាមួយ គឹម ហង្ស ជាមួយ ស៊ូ គឹមស៊ិន ជាមួយស្អីៗហ្នឹង ហើយ លី សេងហុង មនុស្សជិតខាងគ្នា ឥឡូវផ្ទះគាត់លក់បានពាក់ម៉ឺនប្រគល់ឱ្យប្រពន្ធគាត់

បាន២០ម៉ឺនហើយ ផ្ទះគាត់នៅហ្នឹង ។

**សុន ឆ័យ** : អញ្ចឹងបងទិញយកអស់ហើយ ។

**សម្ដេច** : ទិញយកអស់ហើយៗ នែ៎! បាន២០ម៉ឺន ហើយនៅខ្វះ១៧ម៉ឺនទៀត ឱ្យគាត់ទៀតបាននេះហ្នឹង ។ ហេតុអី លី សេងហុង មកនៅហ្នឹងគាត់អាងថាបើសិនមានការអី គាត់មកនៅហ្នឹងជាមួយគ្នា មនុស្សសុទ្ធតែដឹងគ្នាអស់ហើយហ្នឹង។ ប៉ុន្តែដល់ការប្រយុទ្ធចេញពីនេះទៅ ពេលដែលបាក់ទៅគឺត្រូវតាមជាប់រឺគ្នាធំៗ៤កន្លែង ហើយអារ៉ាវប៉េះរប៉ោះប្រហែលជា៣កន្លែងទៀត រ៉ាវប៉េះរប៉ោះតូចៗហ្នឹង បាន ឆែរត់ទៅបំបែកខ្លួនបាន ។ ខ្ញុំនៅស្ដាយបំផុត ខ្ញុំនៅតែបញ្ហាខ្ញុំថាទៅរកយ៉ាងម៉េចដើម្បីឱ្យមនុស្ស៣នាក់ហ្នឹងរួចចាក់ ព្រោះហ្នឹងគឺបណ្ដាញចារកម្មនៅនេះហ្នឹងនៅនឹងវិទ្យុទាក់ទងហ្នឹងបណ្ដោយ ប៉ុន្តែបាត់ទាំងចារកម្មដែលទៅដែរ ចុះវាបាញ់គ្នា ចុះមានអ្នកណាជួយអ្នកណាបានខ្ញុំស្ដាយណាស់ ស្ដាយមនុស្សប៉ុន្មាននាក់នេះ ។

**សុន ឆ័យ** : លោក វ៉េង គាត់ទូរស័ព្ទទៅខ្ញុំនៅអូស្ត្រាលី គាត់ទៅបាងកកជួបក្រុមព្រះពីរបីថ្ងៃ គាត់ក៏ត្រឡប់ទៅវិញ គាត់មើលទៅ ទៅវិញវាមិនកើត អាហ្នឹងនិយាយតាំងពីខែ៧ ដើមខែ៨ គាត់ក៏ប្រាប់ខ្ញុំថា ឆ័យ ឯងត្រូវគិតធ្វើម៉េច ខ្ញុំថាយើងទៅវិញទៅ ខ្ញុំគិតទៅវិញហើយ គាត់ថា ហ៊ី ទៅក៏ទៅ ប៉ុន្តែចាំមើលសភាព-ការណ៍អីកើតឡើង ចាំមើលកាលៈទេសៈយ៉ាងម៉េច គាត់មានទាក់ទងហើយ ដល់អញ្ចឹងខ្ញុំចាំមើលមើល៎ ចាំមើលខ្ញុំទៅ ដល់ខ្ញុំមកវិញ ខ្ញុំចង់មក ខ្ញុំទៅដល់បាងកក... ចង់ដឹងថា គេធ្វើអីខ្លះ ហើយក៏ស្រាប់តែឃើញការប្រកាសគណៈរដ្ឋមន្ត្រីថ្មីនេះ យកកន្លែងគាត់យកអីណាំ ប៉ុន្តែបានតែថាមែនទែនទៅបើបានគាត់មក ព្រោះគាត់តំណាងរាស្ត្រមួយដែរ ។

**សម្ដេច** : អញ្ចេះ នែ៎ ទាក់ទងទៅ ព្រោះឥឡូវបង តាវ សេងហួរ គាត់មកវិញ តាវ សេងហួរ មកពីអញ្ចេះ ខ្ញុំទៅជួបនៅស្រុកបារាំង នាំទាំងប្រពន្ធទាំងអីមក ហើយខ្ញុំក៏បន្ទោសប្រពន្ធហ្នឹងដែរថា បងឯងត្រចៀកស្រាលពេក ថ្ងៃដែលគាត់វ៉ៃហ្វាក់មក ថាហ្វាក់ហ្នឹងវានៅក្នុងកេះតុខ្ញុំទេ គឺ démission របស់គាត់ហ្នឹង គឺថាខ្ញុំអត់មានបញ្ជូនចេញទេ ថ្ងៃហ្នុងប្រពន្ធលេបថ្នាំសំលាប់ខ្លួន អារឿងអី សង្ស័យស្រីមួយដែលសម្ដេចក្រុមព្រះយកក្រោយនោះនៅកៀនស្វាយនេះ អញ្ចឹងគឺថាប្រេះស្បុងធ្ងន់ណាស់ទៅលើបង តាវ សេងហួរ ព្រោះយប់ថ្ងៃទី៨ តាវ សេងហួរ ជួបខ្ញុំតាមទូរស័ព្ទ រួចគាត់វ៉ៃលិខិតមួយផ្ញើរសិទ្ធិឱ្យ ឈា សុង ដឹកនាំចូលរួមប្រជុំគណៈរដ្ឋមន្ត្រីថ្ងៃទី១០ ដល់គាត់ត្រឡប់ទៅណោះវិញទៅវាមានបញ្ហារឿងគ្រួសារ ហ្នឹងហើយគាត់ប្រើសំបុត្រ démission ។ ដល់ខ្ញុំទៅលើកហ្នឹងជួបដល់ទៅពីរដង មកបានជាមួយខ្ញុំពីរដង ហើយខ្ញុំចេះតែបន្ទោសប្រពន្ធខ្ញុំថា បងធ្វើអញ្ចឹងងាប់ ថ្ងៃក្រោយទៅណា មួយជំហានតាមឱ្យជាប់ទៅ ហើយឥឡូវហ្នឹងគាត់មកវិញ ព្រោះយើងបោះឆ្នោតកន្លងទៅហ្នឹងក៏វាអត់ទាន់ជាប់ជាស្ថាពរ មានន័យថាសន្លឹកយើង សន្លឹកឆ្នោតមួយមានន័យ២ ទាល់តែជាប់ឧបមាជាក់តា ចាយ ទាល់តែជាប់តា ចាយ បាន តាវ សេងហួរ ត្រូវអស់ ។ បើមិនជាប់ទេវានៅដដែល ឥឡូវលោក វ៉េង នៅរដ្ឋមន្ត្រីដដែលតើ ។ អញ្ចឹងទេឱ្យមកវិញមក ឥឡូវខ្ញុំនិយាយជាមួយបង ចាយ ហើយខ្ញុំថាឥឡូវដោយសារបង តាវ សេងហួរ គាត់មកវិញ ហើយសល់តែប៉ុន្មាន

ខែទេ បងកុំទៅនេះអីបងធ្វើទីប្រឹក្សារដ្ឋាភិបាលទៅ ទុកឱ្យបង តា សេងហួរ គាត់ធ្វើឱ្យវាចប់កិច្ចការ គាត់ដល់អាណត្តិទៅ គាត់ក៏ដកពាក្យទៅ ហើយ អ៊ឹង ផន គាត់ក៏ដកបេក្ខភាពចេញពីទេសចរណ៍ ហើយបើអញ្ចឹង វ៉េង មកនេះមក គ្មានអី ខ្ញុំថាពន្យារឿងហ្នឹងបន្តិចទៅដូច អ៊ុំង គៀត អី យើងអត់មានប៉ះពាល់ទេ ខ្ញុំថាប្រមូលគ្នាមកធ្វើការអញ្ចឹង ។ បានខ្ញុំឃើញថាប្រសិនជាការគិតខុសណាមួយក្នុងចំណុចដើរ គេមកតស៊ូ ខ្ញុំសរសើរ ថាច់ រ៉េន ថ្ងៃមុនពួកហ្លុងបាយជាមួយគ្នា ឃើញស្រាប់មានមតិ រួចខ្ញុំឃើញថាអញ្ចេះដូចមតិរបស់គាត់លើកឡើងបំភ្លឺ គាត់មានហេតុផលមិនមែនថាគ្មានហេតុផលទេ ដល់យូរៗទៅមតិ ថាច់ រ៉េន និងមតិ ឌិត មន្ទីរ ដូចគ្នា ជជែកពីរឿងប៉ុន្មាននាក់បង្កើត គណបក្សហ្លុង គឺរឿងហ្នឹង គឺយើងមិនត្រូវមើលស្រាលទេ បើមានស្នីមកជជែកក្នុងសភានេះ លទ្ធភាពនេះជាលទ្ធភាពដែលល្អបំផុតហើយ ។ លទ្ធភាពទៅធ្វើដូចជារឿងអី បង្កើតតំបន់អប្បគមន៍ រ៉ែត្នា ឆ័យ អើយ! ឆ័យ ឯង បើសិក្សាសំនុំរឿងហើយ ចាំ ឆ័យ ឯងមកនេះវិញ ខ្ញុំៗអត់យល់ ។ ដំបូងខ្ញុំនឹកស្មានថារឿងនេះ ជារឿងគ្រាន់តែជាការប៉ះទង្គិចចៃដន្យមួយ ហើយដោយសម្ដេចក្រុមព្រះប្រកាស់ល្ងាចហ្នឹង ដល់ទៅស្រាវជ្រាវឯកសារបញ្ចប់ ពិសេសអ្វីដែលខ្ញុំហួសចិត្តខ្ញុំ គឺពាអាទិត្យក្រោយទេ ពាអាទិត្យក្រោយសភាពការណ៍ បានខ្ញុំយល់ថារឿងមិនធម្មតា ។ យកបានផែនទីពីរផ្ទាំងមក ខ្ញុំអត់មានជំនឿថា ពួកហ្នឹងធ្វើមធំដល់ប៉ុណ្ណឹងទេ ។ បានឃើញផែនទីរ៉ៃផ្ទះខ្ញុំហើយឬនៅ ?

**សុន ឆ័យ** : ឃើញ !

**សម្ដេច** : ដល់ទៅយកបានទាំងអាវុធមកទៀត បានខ្ញុំថា យ៉ឺ! អត់ស្រួលទេ អាវុធកប់នៅក្បែរ កប់ជើងឯកនេះហើយ ៥៨០នាក់ សំរាប់រ៉ៃកន្លែងនេះ ដល់ទៅយកបាន Tape បានខ្ញុំវាហួសចិត្ត ចាំយក Tape ហ្នឹងទៅមើល ហើយ ឆ័យ ឯងវិនិច្ឆ័យមើល ល្ងាចថ្ងៃទី៥ ហ៊ានប្រកាសថាខ្ញុំងាប់! មូលហេតុអីបាន ហ៊ានប្រកាសថាខ្ញុំងាប់ ដោយសារសេនារិយោរ៉ៃកន្លែងនេះ វាមិនមែនរឿងតូចតាច ចង់យកផែនទីនេះ ខ្ញុំថតកូល័រឱ្យមើល ។ អ្វីដែលខ្ញុំមិនអស់ចិត្ត គឺនៅត្រង់ហ្នឹងតែម្ដង ខ្ញុំធ្លាក់ទឹកចិត្ត ។

**សុន ឆ័យ** : ខ្ញុំក៏ឃើញអាចំណុចនេះដែលគេរ៉ៃ ហុក ឡុងឌី ទៅរ៉ៃកន្លែងគេ ពួកអស់ហ្នឹងវាទៅថត វាអួសខ្មោចពេលងងិតនុះណា!

**សម្ដេច** : ប៉ុន្តែ ហុក ឡុងឌី មានទៅរ៉ៃ.

**សុន ឆ័យ** : ....ពិសេសទូរទស្សន៍អីវាទៅថតបានមកពួក សេរី កុសល វាទៅអួសខ្មោចដឹកយកមកដាក់នៅហ្នឹង ខ្ញុំមានទុកតើ កាសែតហ្នឹង ។ វាទៅបាញ់មុខផ្ទះគេ វាងាប់ វាអួសអាខ្មោចយកមកដាក់កន្លែងហ្នឹង។

**សម្ដេច** : ហ្នឹងទៅបាញ់គេ ផែនទីទាំងអស់នេះវាមានពាផ្ទាំង មិនមែន២ផ្ទាំងទេ នេះ១ផ្ទាំង យករបស់ ញ៉ឹក ប៊ុនឆៃ រត់ជ្រុះនៅឧត្តុង្គ ហើយនេះគឺរបស់ ហូ សុខ យកបាននៅការិយាល័យ ហូ សុខ ប៉ុន្តែអ្នកដែលបញ្ជារ៉ៃ នៅមុខព្រួញនេះ គឺប្អូនរបស់លោក ឈឹម ឈន គឺលោក ឈឹម សាខន នោះណា គឺ គាត់ថាមិនមែន២ផ្ទាំងទេ មានពាផ្ទាំងនៅលោក សោម ណារិន មួយទៀត ។ អានេះខ្ញុំកំពុងតែឱ្យតាមរក អានេះផ្ទះដែលយើងកំពុងអង្គុយនេះ អញ្ចឹងត្រូវរ៉ៃអានេះ.

**សុន ឆ័យ**: នេះ១ មូលដ្ឋានយោធាគេមួយនេះ ។

**សម្ដេច** : នេះគេរើចេញពីតាកែវមកឱ្យ ឈឹម សាខន ឈឹម សាខន ប្អូន ឈឹម ឈន អ្នករើ រើតាមហ្នឹង ដូច្នេះឥឡូវអាវុធដំបូង គឺ ញ៉ឹក ប៊ុនឆៃ ឱ្យយកមកទំលាក់នៅទីនេះ ដើម្បីរើចូលផ្ទះខ្ញុំនេះ ប៉ុន្តែ សេនាជាតិ ប្រធានកងពល៦០៣ របស់ខ្មែរក្រហម ថាមិនអាចយកទំលាក់នៅទីនេះទេ ទំលាក់នេះ! ដល់ទំលាក់នេះ ដើម្បីរើសំរាប់មួយមុខព្រួញនេះ គឺថារើកាត់មកនេះភ្លាម ហើយមីន៨០គ្រាប់ក្នុងនោះ ៣០គ្រាប់សំរាប់ផ្តាច់ស្ពាន់នេះ ហើយមួយមុខព្រួញទៀតសំរាប់រើទៅស្ទឹងមានជ័យវិញ។ អញ្ចឹងកាំភ្លើងទីនេះ ៣ឯកត្តា ៣ឯកត្តាដែលគេបំពាក់នៅទីនេះ ដែលខ្ញុំវាហួសចិត្តខ្ញុំ ធម្មតាគឺការបំពាក់អាវុធណាក៏ដោយ គឺគេអត់លេងដល់៣ឯកត្តាអញ្ចឹងទេ គឺមិនងាយទេ ទាល់តែថាសង្គ្រាមហ្នឹងធំណាស់ អញ្ចឹងគេអាចយកកន្លែងហ្នឹងជាកន្លែងមួយ ។ អាវុធនៅជើងឯក ដែលគ្រាប់បេ៤០ ធម្មតាគេបំពាក់តែ៤គ្រាប់ទេក្នុង១ដើម តែនេះបំពាក់១២គ្រាប់ក្នុង១ដើម អញ្ចឹងអាវុធ ហើយនេះអាំបារ៉ាស់ទាំងអស់ជាង៣០០ដើម ដែលយើងយកបាននៅទូទាំងប្រទេស នេះគេត្រូវរើចេញពីកោះខ្សាច់ជលាមកផ្ទះ ហូ សុខ នៅម្តុំនេះស្រាប់យើងយកនៅទីនេះបានជាប់ជិត៩០ដើមដែរ. ដើម្បីកាន់កាប់សាលាស្រុកស្លាង អញ្ចឹងតំបន់ទាំងអស់នេះ គឺសុទ្ធតែយកបានទាំងអស់ កំលាំងត្រូវប្រើ៩៨០នាក់ នេះ១០០, ត្រង់នេះ៨០, ត្រង់នេះ៧០ គេដាក់សុទ្ធតែមានចំនួន ហើយអ្នកគូផែនទីនេះមិនមែនជាអ្នកគូផែនទីផ្នែកយោធាទេ ព្រោះអត់ចេះគូសញ្ញាទេ ដោយសារផែនទីនេះជាផែនទីសំងាត់នៃការរើ ។ អញ្ចឹងបានជា លី ធុច មានលទ្ធភាពនិងនិយាយថាខ្ញុំស្លាប់តាំងពីការផ្ទុះអាវុធតែប៉ុន្នាន រួចហើយ ឆ័យ ឯងចំមើលចាំពិនិត្យមើល តើនរណាធ្វើនរណា ? បើគេអង្គុយផឹកតែបញ្ហានោះ រឿងគេអង្គុយផឹកតែបញ្ហាមិនមែនបានសេចក្តីថាគេភ័យដោយយើងរើគេនោះទេ គេរើយើង ។

**សុន ឆ័យ**: ខ្ញុំឆ្ងល់កាលថ្ងៃទី៤ ខ្ញុំទៅជប់លៀងនៅទូតអាមេរិកាំង នៅជិតពូវន្តមានប៉េអឹមហ្នឹងខាង FCP ម្នាក់ គេទៅ អ្នកធំនោះណា៎ គេទៅប៉ុន្នាននាក់ទេណា៎! ខាង FCP បាត់ទាំងអស់អត់មាននរណាទៅម្នាក់ គេរៀបជើងព្រួលតាំងពីយប់ឯណោះ ។

**សម្ដេច** : តាំងពីយប់ហ្នុងថា នែ៎! វិទ្យុខ្មែរក្រហមនិយាយវាហួសចិត្ត ឥឡូវ ឆ័យ ឯងមើលវិទ្យុខ្មែរក្រហមមកនៅត្រង់ហ្នឹង វាមកនៅតាំងក្រសាំង ។ អញ្ចឹងបានយើងចាំណាស់ថ្ងៃទី១១ ខែ៦ គេប្រកាសថាវិទ្យុខ្មែរក្រហមត្រូវបានកំទេច ហើយថ្ងៃទី១៤ ខែ៦ ផ្សាយឡើងវិញឮលើសដើម ឥឡូវមកនៅតាំងក្រសាំងវាមកនៅតាំងក្រសាំង វាអញ្ចឹង ឥឡូវយើងធ្វើម៉េច ? រឿងនេះអានេះ យូ ហុកគ្រី ក៏គាត់ធ្វើជាសាក្សីឱ្យដែរ អារឿងហត្ថលេខាជាមួយនឹងខ្មែរក្រហម រឿងហ្នឹងអស្ចារ្យអានេះថតផែនទីដែលល្ងាចថ្ងៃទី៣ គឺ ឆៃ យកអាហ្នឹងមកដល់តំណាក់ ពេលហ្នឹង យូ ហុកគ្រី នៅហ្នឹង អញ្ចឹងមកពេលនេះស៊ីញ៉េតា ខៀវ សំផន, ញ៉ឹក ប៊ុនឆៃ, ទេព យុនណាល់ ថ្ងៃទី៣ ខែ៧ ជ្រុលដៃគេជ្រុលដៃដាក់ថ្ងៃទី៣ ខែ៧ រួចហើយល្ងាចសម្ដេចក្រុមព្រះអត់ទាន់ស៊ីញ៉េទេ ឯកឧត្តម យូ ហុកគ្រី អ្នកនិយាយប្រាប់ខ្ញុំ គឺអត់ទាន់ស៊ីញ៉េទេ ដោយលោក ឡាយ ថា ខ្ញុំទៅប្រសាទព្រះវិហារ ដោយសារថាអី នៅប្រសាទព្រះវិហារអីណា៎ អញ្ចឹងទេថាអត់ទៅ ប៉ុន្តែចំណុច២នេះអាចមាន២ ទី១អាចពិត

ទី១ អាចលោកធ្វើអញ្ចឹងទៅដើម្បីបំភ័ន្តភ្នែក យូ ហុកគ្រី ព្រឹកឡើងថ្ងៃទី៤ ព្រលឹមឡើងចេញដំណើរ ហើយរឿងអញ្ចឹង២ ឆ័យ មើល ហើយទ័ពខ្មែរក្រហមស្លាប់ប៉ុន្មាន FCP ពិតប្រាកដ ស្លាប់ប៉ុន្មាន? បើនិយាយពីអង្គរក្សសម្តេចក្រុមព្រះ គឺស្លាប់តែ១ទេ ស្លាប់តែ១ គឺស្លាប់ដោយសាររេលកៃកាំភ្លើងទៀត អង្គរក្សខ្ញុំពលីអស់ ៤ របួស៨ កាត់ជើង២ដើម្បីយករថក្រោះទៅទប់ បើកុំទប់ឯណាទាន់ណាំក្រុងភ្នំពេញយ៉ាប់។ វាមានអ្នកណាអាកន្លែងហ្នឹង! ខ្ញុំមកដល់ខ្ញុំចាំអាថ្ងៃដល់ដែលនេះមក ថ្ងៃដែលខ្ញុំឮរដ្ឋប្រហារបងប្អូន បញ្ជូនឧទ្ធម្ភាគចក្រមកយក ដល់ចន្លោះខ័ណ្ឌវត្តភ្នំ អានេះវាហោះពីនេះទៅវាហោះ៦ដល់អាពាមកនេះ វាទៅណោះ វាបឺះឧទ្ធម្ភាគចក្រខ្ញុំត្រូវខ្មាត យ៉ាន បញ្ជាឱ្យ២ឡើង២ទៅអមខ្ញុំចុះយកមក ។ ដល់ថ្នាក់ខ្ញុំដាក់បញ្ជាទី១ គឺពោធិចិនតុង ខ្ញុំអត់ឱ្យប៉ះពាល់ ទី២តាំងក្រសាំងជាទីតាំងស្រប់ច្បាប់របស់រដ្ឋាភិបាល ផ្ទះសំណាក់ រណប្ញទ្ធិ ទី៤ ទោះបីមានការបាញ់គ្នាច្រើនជាងនេះក្តី ហើយផ្ទះចៅ សម្បត្តិ បាញ់យ៉ាងម៉េចក៏ដោយគឺយើងកុំអាលធ្វើអី ខ្ញុំរកទាក់ទង ។ យប់ម៉ោង ១២:០០ យប់ថ្ងៃទី៥ គ្រាន់តែឃើញទូរស័ព្ទទៅ សុខ អាន សួរទី១លោក ហ៊ុន សែន ងាប់មែនឬអត់ ទី២បើលោក ហ៊ុន សែន នៅរស់ តើចរចាជាមួយសម្តេចក្រុមព្រះ ? ខ្ញុំថាឱ្យតែលោកទូរស័ព្ទមកដើម្បីរក ហើយខ្ញុំសំរេចចិត្តនេះឱ្យខ្ញុំសំរេចចិត្តចូលកាន់កាប់អានេះ និងអានេះ គឺនៅម៉ោង១:៣០នាទីក្បែរភ្លឺនោះទេ ៥:៣០នាទីក្បែរភ្លឺ បានចាប់ផ្តើមផ្ទុះ ផ្ទុះទៅអានេះគេវៃ ចាំ សុន ឆ័យ ឯងមើលក្នុង Tape ចល័តចេញតាំងពីមកនៅក្នុងក្រុង ព្រលឹម១ឡើងគឺចល័តចេញពីតាំងក្រសាំង ចល័តចេញតាមគឺចល័តចេញទៅតាមមើល ហើយអញ្ចឹងបានព្រលឹមឡើង វាមិនដែលមានរដ្ឋមន្ត្រីការពារជាតិនិងអគ្គសេនាធិការរត់ទេ យើងដើរនៅឈរបញ្ជាគេហ្នឹងរត់ទៅណារួចមកនៅជាមួយខ្ញុំនៅហ្នឹង ព្រលឹមឡើង អញ្ចឹងវាសិយខ្ញុំទៅទៀត អង្គរក្សខ្ញុំត្រូវចេញទៅតាកែវដើម្បីការពារឱ្យខ្ញុំ ថ្ងៃច័ន្ទត្រូវទៅសម្តេចទំនប់ទឹករបស់សហគមន៍អឺរ៉ុបពួកបាសាក់នោះ ។ អញ្ចឹងវាអត់ទាន់មកពីតាកែវ ដល់អញ្ចឹងខ្ញុំត្រូវចាប់បង្ខំប្រើបានតែថ្មើរជើងជាង១០០នាក់ និងរថក្រោះ៣ទេ ឡើងទៅហ្នឹងដើម្បីយកប្រើដើម្បីទៅវៃអានេះ គឺទំរាំអានេះឡើងមក អានេះឡើងមកយើងអាចវៃអានេះទៀត វៃទៅ..... ប៉ុន្តែអ្វីដែលយើងដឹងស្លាប់តែ២ទេ បងប្អូនដែលមកតាមនេះ មកពីភូមិភាគ២មកឆ្លងកាត់អានេះបាញ់ស្លាប់ម្នាក់ របួសម្នាក់ របួសម្នាក់យកទៅពេទ្យស្លាប់ទៀត។ ប៉ន្តែអ្វីដែលយើងដឹងដែលដល់ពេលយើងកាន់កាប់ហើយ គាត់ទៅហើយបានយើងឃើញថាខ្មោចនៅ៥នាក់នៅហ្នឹងទៀត រាប់ទាំងតែកុងឡានអំបូង់របស់ពេទ្យកាល់ម៉ែត្រ ក៏គេបាញ់ធ្លាយពោះស្លាប់ គាត់ជិះម៉ូតូដើម្បីមកបើកអំបូង់ បាញ់ស្លាប់៥នាក់ទៀត បូកសរុបស្លាប់៧នាក់នៅនេះ អញ្ចឹងចំលងទ័ពមកដល់នេះហើយ បើវៃពួកនេះចេញពីនេះ ព្រោះពួកនេះកំពុងនៅបុកនៅត្រង់ហ្នឹង បើវៃពួកនេះចេញពីនេះមក ដូចវៃឱ្យមកចូលក្រុង អញ្ចឹងត្រូវឱ្យពួកនេះស៊ីវៃក្បាលនៅនេះទប់ឱ្យជាប់ឱ្យពួកនេះមក មកដល់ត្រង់ហ្នឹង។ ឆ័យ ឯងគិតមើល ម៉ោង៣:០០ ហើយវាអស់ប្រេងនៅទីនេះ ហើយប៉ុស្តិ៍វិទ្យុស្អឹងមានជ័យរត់អស់ហើយសល់តែ៣នាក់ ហើយអស់ទាំងប្រេងទៀត ខ្សែភ្លើងដាច់អស់ផ្សាយលែងចង់ចេញហើយ ។ អញ្ចឹងត្រូវចំលងប្រេងយកទៅឱ្យវាដល់ម៉ោង៤:០០ហើយ បានចាប់ផ្តើមឱ្យរថក្រោះ៧គ្រឿងឡើងវិញ វៃវិញ ហើយចាំមើលក្នុង អា Tape ហ្នឹង ។

**សុន ឆំយ:** ព្រលប់ៗទើបផ្សាយហើយ ផ្សាយទូរទស្សន៍ឱ្យគេឃើញទេ ?

**សម្តេច** : ផ្សាយៗ ផ្សាយហ្នឹងហើយបានប្រជាជនចាប់ផ្តើមភ្ញាក់ចុមរឿងនេះមិនធម្មតាឯណា ហើយបរទេស ឥឡូវនេះ គឺថាដល់ពេលយើងបញ្ជូនឯកសារទៅ ឥឡូវអញ្ចេះ រឿងនេះវាបានដើរដល់អញ្ចេះ ឥឡូវហ្នឹងវាអត់មានការអើលើសពីហ្នឹងទេ ហើយដើរទៅដល់នេះហើយ ដើរទៅដល់ដំណាក់កាលគេហៅថាលែងហ៊ានតវ៉ាផ្លូវច្បាប់ហើយ ។

**សុន ឆំយ:** ....ប៉ុន្តែតាមមេធាវីថាបងមានវ៉ៃ Paper ថ្មីមួយទៀតហ្នឹងណាំ អាហ្នឹងយ៉ាងណាគេសន្និដ្ឋានទេណាំ មួយប្តឹងបង វែង មិនដឹងជារឿងស្អីខ្លះទេ បែបគេភ័យខ្លាំងហើយ បែបចាំចប់ហើយបាននេះ គេប្រគល់អានេះ អានេះគេប្តឹងវិញ ព្រោះពួតាមតេឡេហ្វូន... ដើម្បីធ្វើប្តឹងមកវិញ ។

**សម្តេច** : ព្រោះរឿងហ្នឹង វាមិនមែនចង់ប្តឹងអីទេ ប្តឹងពីរឿងយើង អាត្រង់ហ្នឹងហើយ អាវ៉ៃ Paper ទី២នេះ ប៉ុន្តែអានេះ ដោយសារបងប្អូនថតនឹងកូល័រ ថតចេញពីផែនទីអាម្បាញ់មិញ រួចអានេះខ្ញុំគ្រាន់តែគូសរបស់ខ្ញុំចំណាំ ហើយឃើញមានអាវ៉ៃ Paper ទី២នេះ គឺឥឡូវអក្សរពីណា ? អានេះអក្សរ ញ៉ឹក ប៊ុនឆៃ ដែលខ្ញុំតែងតែប្រកាស ខ្ញុំថានៅអន្លង់វែងវាអត់មានកុំព្យូទ័រទេ កុំព្យូទ័រវាចេញពីភ្នំពេញ ទី១យើងមានមនុស្សរបស់យើងនៅកន្លែងណា បានគេរាយការណ៍មកឱ្យខ្ញុំ ខ្ញុំថាខ្ញុំព្យាយាមប្រាប់សម្តេចក្រុមព្រះហើយណាំ កុំធ្វើណាំព្រះអង្គ តែធ្វើខុស ។ ហើយឥឡូវនេះអក្សររបស់សម្តេចក្រុមព្រះគោរពឯកឧត្តម ខៀវ សំផន ជាទីរាប់អានដ៏ខ្ពង់ខ្ពស់ពីណាំ ស្អីៗនេះ ។ អាហ្នឹងឆ្លើយតបទៅនឹងលិខិតរបស់ ខៀវ សំផន នេះ ថ្ងៃទី២៦ ខែមិថុនា នេះថ្ងៃទី២៧ ដល់វាចេញរឿងច្រើន អាហ្នឹងយកទៅតែម្តង ។

**សុន ឆំយ:** ...ហើយបើយើងរកបាន រកនរណាមួយដែលគេទទួលស្គាល់ជាអន្តរជាតិ...ដើម្បីទទួលស្គាល់យើងយល់ថា វាពិតបាកដែរហ្នឹងពីព្រោះបើយើងគិតថា ពាក់ព័ន្ធដែលគេធ្វើបាបយើងហ្នឹងណាំ! វារករឿងនោះណាំ ប៉ុន្តែរកមនុស្សណាដែលគេអាចជនបរទេសណាដែលល្អមថា និយាយទៅគេស្គាល់យើងណាំ យកពួកហ្នឹងចេញមកហ្នង ។

**សម្តេច** : អញ្ចឹងយើងយកមនុស្សវៃឱ្យហើយតែម្តងវៃឱ្យហើយសំរាប់ វីហ្គេន ជាអវកាដែលធ្វើការជាមួយនឹង វីហ្គេន តែម្តង...ហើយដល់ពេលអញ្ចឹងបានជាយើងរុញអាហ្នឹងទៅឱ្យអាស្អី ខ្ញុំថានែ៎ ខ្ញុំសូមជំរាបស្រាប់តែពួកហ្នឹងដឹងបាត់ទៅហើយ ថាយើងយកមនុស្ស វីហ្គេន យកមកទុកធ្វើតែម្តង ហើយស្អើខ្ញុំទៅញ៉ូវយ៉កនេះ ខ្ញុំវៃហ្វាក់ឱ្យគាត់ដឹងថា ខ្ញុំត្រូវចេញពីណោះហើយ គឺឱ្យគាត់ចេញពីភ្នំពេញទៅដើម្បីឱ្យគាត់ទៅ ឥឡូវគាត់មកធ្វើការនៅភ្នំពេញហើយ ដល់គាត់ប្រើពាក្យចេះខ្មែរ ឥឡូវគាត់ចេះខ្មែរ១ម៉ាត់ៗ គាត់ថា អាមេរិកាំងឡប់ៗ ។ ខ្ញុំវាហួសចិត្តត្រង់រឿងគេថា ងាប់ហើយ ហើយប្រើពាក្យថា FCP វាមិនត្រង់រឿងអី បើគេចាត់ទុកថាខ្ញុំជាមនុស្សម្នាក់ដូចគេដូចឯង បើសិនជាខ្ញុំស្លាប់ កំគង់គេត្រូវតែមានការសោកស្តាយតិចតួចដែរ តែនេះគេនិយាយទាំងទឹកមុខញញឹមចាំមើលទៅ ថាស្លាប់ហើយ ស្លាប់ដោយអង្គរក្សខ្លួនឯងសំលាប់។ ពាក្យខ្មែរគេថាប៉ះទង្គិច ។

**សុន ឆ័យ :** រឿងនេះ ប៉ុន្តែវាអញ្ចេះ រឿងមួយទៀតបងត្រូវតែដឹងរាស្ត្រសព្វថ្ងៃនេះ ខ្ញុំមកមួយព្រឹកខ្ញុំដើរហូត គេអត់សប្បាយចិត្តហ្នឹងព្រឹត្តិការណ៍នេះ ទី១មានជីវភាពគ្នាវាជុនដាប ហើយមួយទៀតពួកអាកាសែត វាចេះតែថា បងវាបង្កើតរឿងបងអ្នកធ្វើ អាហ្នឹងពួកអាកាសែត ជល់អញ្ចឹងទៅតាមតូបតាមអីហ្នឹង ពួកហ្នឹងវាទៅជាអាណិតក្រុមព្រះ ក្រុមព្រះដាច់អស់ សព្វថ្ងៃយើងឃើញហើយក្រុមព្រះមានតែក្បាលអណ្តែតតែលតោល ខ្លួនគាត់ដូចអត់មានអីសោះ ហើយប៉ុន្តែបើសិនណាជាគាត់មកវិញ ដូចបងជ្រាប់ស្រាប់ហើយ គាត់បោះឆ្នោតក្នុងឆ្នាំ១៩៩៣ មានតែគេស្រឡាញ់ស្គាល់នយោបាយរបស់ FCP យ៉ាងម៉េចអីយ៉ាងម៉េច... ប៉ុន្តែចំពោះការវិភាគរបស់បរទេសគឺអត់ចូលចិត្តក្រុមព្រះទេ ប៉ុន្តែគេរុញក្រុមព្រះរុញ រុញចូលមកអន្តរជាតិអមដំណើរព្រះអង្គ ដើម្បីឱ្យក្រុមព្រះជណ្តើមអំណាចតែឯងនោះគឺ នាយករដ្ឋមន្ត្រីទី១ស្របច្បាប់ រុញៗមក ប៉ុន្តែចុងក្រោយដឹងយ៉ាងម៉េចទេ? វារុញចេញ ហើយវារុញ សម រង្ស៊ី ចូលអត់មានទេ រណឫទ្ធិនេះវាគិតហើយ ប៉ុន្តែវាអត់និយាយឱ្យដឹង រណឫទ្ធិ ចូលទៅ ខំទៅដើរធ្វើនាយករដ្ឋមន្ត្រីទី១ គិតតែខំធ្វើអញ្ចឹងទៅ នេះជារឿងទី១ និយាយពីរឿង រង្ស៊ី និង រ៉ាដា កំពុងតែបែកបាក់គ្នាបាត់ប្រជាប្រិយ៍ធ្វើឱ្យមានបញ្ហាមានអីនេះជំរាបបងត្រង់នៅបរទេសអាមេរិកវានាំគ្នាបំផុសអារឿង រង្ស៊ី ហ្នឹងណាំ បើយើងហ៊ានតែនិយាយថាគាំទ្របងឯងក៏ពុំសូវហ៊ានដែរ ស្រួលមិនស្រួលឆូតឈ្មោះចោលទៀត ចំណុចទី១បងសិក្សារឿងនេះឡើងវិញខ្ញុំចង់ជំរាបបង កាលពីឆ្នាំ១៩៩៣ ពីរបៀបធ្វើការធ្វើអី ពួកនេះវាចង់ឱ្យអន្តរជាតិចូលមក...................... វាចង់ធ្វើឱ្យបញ្ហាសត្វា.....ដូចខ្ញុំនិយាយអញ្ចឹង ឧបមាថាវាចោទពួកថ្លែងការណ៍ ឬអង្គការសហប្រជាជាតិវាយការណ៍មក ធម្មតាគេទទួលស្គាល់ហើយយើងថាពុំមែនយើងពិបាកប្រកែកជាមួយវាណាស់ ហើយបើខ្ញុំជានាយករដ្ឋមន្ត្រីខ្ញុំអត់អញ្ចឹងទេ បើសិនជាមានអាណាធ្វើ...... ពេលណាមួយយើងត្រូវតែធ្វើក្នុងកាលៈទេសៈច្បាប់ ។ ប៉ុន្តែបើដឹងច្បាប់ខ្លាចអីឱ្យជាប់ទោស១ខែ ឬ២ខែទៅ ពីព្រោះយើងធ្វើអញ្ចឹងទេវិញ ខ្ញុំមើលកាសែតមើលអី F.B.I វាទៅធ្វើទៀតសំរាប់យើងវាអយុត្តិធម៌ពីរឿងហ្នឹង វាអយុត្តិធម៌ ប៉ុន្តែបើនិយាយពីសរសេរប្រឆាំង វាខាតកាន់តែខ្លាំង អញ្ចឹងបានយើងធ្វើរឿងហ្នឹងដើម្បីប្រែរូបភាព ហើយបងមានប្រសាសន៍ច្រើនពេក ខ្ញុំទាញឧទាហរណ៍ ពីព្រោះយ៉ាងម៉េចចំពោះថ្នាក់ដឹកនាំគ្លើបល (Kleebio) ប្រទេសកុងហ្គោ បើសិនណាពេលសម្តេចបានឡើងទស្សនៈកិច្ចក្នុង១ខែម្តងទៅទស្សនៈកិច្ចប្រទេសនេះ វាបាត់បង់លក្ខណៈម្យ៉ាងដូចបងជានាយករដ្ឋមន្ត្រីបើហាមាត់ម្តងដូចជាសម្បើមណាំ អាហ្នឹងវាអាចជាលក្ខណៈបច្ចេកទេសទេ..... ហើយក្រៅពីហ្នុងខ្ញុំមើលតាមខេត្តតាមអីដូច.....ដូចគេខំទាញប្រជាប្រិយ៍ភាព។ ចំពោះគណបក្សប្រជាជនគឺរបស់ប្រជាជនតើយើងបានធ្វើដូចអញ្ចឹងទេ គណបក្សប្រជាជនដើម្បីប្រជាជន តើដើម្បីប្រជាជនយើងបានធ្វើអីខ្លះហើយ ? គឺដោយសារតែយើងមានមេឃុំ ដោយសារតែគាត់មានសន្តិសុខ ខ្លះបានខំធ្វើឱ្យយើងល្អ ពីព្រោះយើងមិនឱ្យខុស.......។ ចំពោះអ្នកធ្វើការប៉ុយរ៉ូត្រូវឱ្យមានការផ្លាស់ប្តូរធ្វើឱ្យមាននយោបាយផ្លាស់ប្តូរត្រឹមត្រូវ គណបក្សប្រជាជនដើម្បីប្រជាជនឱ្យប្រជាជនស្រឡាញ់យើងបង្ខំឱ្យស្រឡាញ់មិនបានទេ អង្វរគេឱ្យស្រឡាញ់មិនបានទេ អារឿងនេះខ្ញុំសូមអង្វរបងកាលណាបងប្អូនជួប

គណបក្សប្រឆាំងវាស្រែកជេរយើងស្អី យើងដោះស្រាយបានមុនអានេះវាអត់មានរឿងទៅកកូរកកាយអីកើតទេ គិតមុនអ្នកឯង អ្នកស្រែកពីរឿងអី? ពីរឿងពុករលួយ ឧទាហរណ៍ ខ្ញុំបង្កើតគណៈកម្មការពុករលួយស៊ើបអង្កេតរឿងអីប្រឆាំង សុន ឆ័យ បញ្ហារឿងដាក់មនុស្សវាធម្មតាទេ យើងទៅធ្វើបាបគ្នាឯងម៉េចនោះ ដូចសព្វថ្ងៃអញ្ជឹងយើងត្រូវការមនុស្សធ្វើការ។

**សម្តេច** : ឥឡូវ ឆ័យ ឯងអាចជួយរួមចំណែកធ្វើអានេះមួយដែលកន្លងទៅគឺបានផ្តើមគំនិត ហើយដូចជាមានការស្រុះស្រួលគ្នាច្រើន ហើយអំពីគណៈកម្មាធិការជាតិខាងសិទ្ធិមនុស្សមួយដែលឯករាជ្យពីដើមយើងជជែកគ្នាយ៉ាងច្រើនក្នុងសភា យើងបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សរបស់សភា ប៉ុន្តែទៅរូបមន្តរបស់ហ្វីលីពីន គេធ្វើមានគណៈកម្មាធិការជាតិចំរុះមួយក្នុងរដ្ឋសភាជាតិ ប៉ុន្តែបង នៅ កាស៊ី គាត់ចង់បានចែងក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែយើងធ្វើវិសោធនកម្មធម្មនុញ្ញទៅមិនទាន់រួចទេពេលនេះ ហើយខ្ញុំក៏បានទៅប្រជុំនេះដោយមានការស្រុះស្រួល ហើយខ្ញុំឱ្យខាងថវិការបស់រដ្ឋាភិបាល ប៉ុន្តែប្រគល់ទៅអង្គការក្រៅរដ្ឋាភិបាលជាអ្នកព្រៀងច្បាប់ហ្នឹង ស្តីពីគណៈកម្មាធិការជាតិខាងសិទ្ធិមនុស្សនេះ ហើយបង្កើតឡើងដោយខ្ញុំចង់ថា អ្នកដែលកើតឡើងមិនមែនទៅជាអង្គការមួយរបស់រដ្ឋាភិបាលទេ ក៏ប៉ុន្តែយើងប្រគល់ដាវទៅឱ្យគេតែម្តង ទៅលើបញ្ហាសិទ្ធិមនុស្សនេះវាល្អជាង ប៉ុន្តែឥឡូវកុំឱ្យរដ្ឋាភិបាលជាអ្នកព្រៀងទុកអារឿងហ្នឹងឥឡូវ អាដហុក គឺបានខាងលោក ធន សារ៉ាយ គាត់បានព្រៀងថា មានពង្រៀងថា មានពង្រៀងហ្នឹង ហើយខាង លីកាដូ ថាគេមានដែរ ឥឡូវខ្ញុំថាអស់លោកយកទៅធ្វើម៉េចកែឆ្នៃដូចម្តេចហើយចង់បានអី ចង់បានអីប្រគល់អាហ្នឹងឱ្យតែម្តង ខ្ញុំថាបើបញ្ហាខាងមុខយើងធ្វើបានជំហាននេះព្រោះរឿងនេះមិនចាំបាច់មានបរទេសមកទេ ព្រោះអារឿងនេះអនាគតយើងទាំងអស់គ្នាទេ ទី១ បញ្ហាអព្យាក្រិត្យភូបនីយកម្ម កំលាំងប្រដាប់អាវុធនិងរដ្ឋបាលស៊ីវិល រឿងនេះយើងបានធ្វើតាំងពី ៩៣, ៩៤, ៩៥ ទើបមកខូចការត្រឹម៩៦ ពេលដែលសម្តេចក្រុមព្រះប្រកាសនៅក្រុងព្រះសីហនុ ថ្ងៃទី២០/០១/៩៦ អំពីតុល្យភាពនៃកំលាំង បើកាលណាយើងបង្កើតអាហ្នឹងអត់បានទេ..........។

**សុន ឆ័យ** : .............. ចំពោះគណបក្សប្រជាជនទៅថ្ងៃមុខ សូមឱ្យយើងបង្កើតការងាររដ្ឋបាលនៅកណ្តាល អាហ្នឹងចំពោះបញ្ហាទី១យើងអាច..... ប៉ះច្រើនមិនបានទេមនុស្សដែលគេស្គាល់មូលដ្ឋានក៏គេស្គាល់កំលាំងគេ អានេះបើយើងទៅលូកច្រើនពេកទៅវាបាក់ទឹកចិត្តគេដែរ ទីបំផុត.... មិនមែនលើកដាក់ដូចពួក FCP កាប់ជ្រូក ទៅខាងគេឯណាអត់បានទេ អានេះជាគំនិតមួយដែលដោះស្រាយបញ្ហា កាប់គោពីណាក៏ដោយឱ្យតែអ្នកនោះមានសមត្ថភាពធ្វើការ កុំថាគេ អ្នកនេះអ្នកនោះកុំឱ្យគេអន់ចិត្ត គេចោទប្រកាន់ថាគណបក្សប្រជាជនគ្រប់គ្រងរដ្ឋបាលអានេះជាការពិត ប៉ុន្តែក្រុមព្រះបញ្ញាពួកនេះមើល បើធ្វើតាមអប់រំយ៉ាងម៉េចឱ្យយើងមានការចេះដឹងខ្លះមួយចំនួនធ្វើការបានភាគច្រើនហើយគឺ១០អីបាត់តែ២អីទេ វាគួរដែរ ......ទី២គេជួយគាំទ្របងឯងយកទៅដាក់ឱ្យពួកអានេះ ថាយើង....យើងត្រូវអប់រំគេឱ្យមានការយល់ដឹងខ្លះ ។

**សម្តេច** : អាហ្នឹងខ្ញុំបាននេះហើយ ឥឡូវនេះយើងអាចបញ្ចូលបានប្រហែល ៥០ ទៅ ៦០នាក់ភ្ញាម កាលហ្នឹងគឺ

ខ្ញុំបាននិយាយប្រាប់បង ចាយ ក្តី ថាកុំឱ្យនិយាយតទៅទៀត រឿងគណបក្សក្នុងគណបក្ស ក្នុងគណ-បក្សក្នុងរដ្ឋាភិបាលនិងកងទ័ពក្តី គឺឈប់និយាយ ប៉ុន្តែយើងធ្វើអញ្ចេះ ឥឡូវទូទាំងប្រទេសមានចៅ-ហ្វាយស្រុកចូលនិវត្តន៍អស់ម៉ាសន្ធឹកអត់ទាន់និយាយមិនទាន់ដាក់បំពេញថែមទេ អនុស្រុកមួយចំនួនក៏អត់ផង ដូចជាស្រុកក្រឡាញ់អត់មានចៅហ្វាយស្រុកផង ឥឡូវខេត្តកំពង់ចាមយើងនៅតាមស្រុក មានស្រុកតំបែ មានកំពង់សៀម មានមេមត់ មានស្ទឹងត្រង់ មានបាធាយ ។ ៥ស្រុកអត់ទាន់មានចៅហ្វាយស្រុក អញ្ចឹងយើងគួបផ្សំគ្នាបានគឺអញ្ចេះ ឥឡូវកាលពីមុនមន្ត្រីរបស់ FCP ឬក៏ B.L.D.P ដែលបានបញ្ចូលក្នុងក្របខ័ណ្ឌនោះណា៎ យើងយកទៅហ្វឹកហ្វឺនបងប្អូនខាងផ្នែករដ្ឋបាលមួយចំនួន រួចហើយសាលារដ្ឋបាលដែលបានបណ្តុះបណ្តាលចេញមកហើយនេះ ។ ឥឡូវថាយើងខ្វះចៅហ្វាយស្រុក ១០នាក់ យើងយកបេក្ខជន២០នាក់យកមកធ្វើតេស្តមក មិនអញ្ចឹង យកទៅធ្វើតេស្តទៅ រួចយកទៅដាក់ទៅកុំនិយាយរឿងគណបក្ស ឬមិនគណបក្សទៀតឱ្យវាចប់តែប៉ុណ្ណឹង ។ បើកាលណាធ្វើអាហ្នឹងបាន យើងមើលប៉ុណ្ណេះ បទពិសោធន៍នៅប៉ូឡូញ បទពិសោធន៍នៅអឺរ៉ុបខាងកើត បទពិសោធន៍នៅអតីតសហភាពសូវៀត ដែលចែកទៅជារដ្ឋ ពួកកុំម្មុយនីសគ្រប់គ្រងកងទ័ព នឹងគ្រប់គ្រងរដ្ឋបាលរាប់សិបឆ្នាំហេតុអីបាន......អាចឈ្នះឆ្នោតបាន ដោយសារគេអព្យាក្រឹត្យបាន កន្លងទៅបើសិនសម្តេចក្រុមព្រះផ្តល់នយោបាយឆ្នាំ៩៣-៩៤ គណបក្សប្រជាជនអស់មូលដ្ឋានបាត់ទៅហើយ បាត់មូលដ្ឋានទៅហើយបានសេចក្តីថា លោកដើរចំប្រឡោះតែម្តង២ ហើយយើងក៏សប្បាយចិត្តដែរ ព្រោះបើទោះបីយើងចាញ់ឆ្នោតក៏គ្មាននរណាមកកាប់សំលាប់យើងដែរ ប៉ុន្តែដល់សម្តេចក្រុមព្រះមុននេះ មុនជំបូងលេងអាគុល្យ-ភាពកំលាំង ដល់មកនិយាយក្រឡុះសាក្នុងសមាជក្រឡុះសារអំពីបញ្ហាបៀវត្ស ឥឡូវមកដល់ពេលនេះបញ្ហាចៅហ្វាយស្រុកដែលចូលនិវត្តន៍ អនុស្រុកដែលចូលនិវត្តន៍ អត់ទាន់មានដាក់ជំនួសទេ គឺថាទាំងពីមុខនេះអាចដាក់បានប្រហែលជា ៥០ ទៅ ៦០ទៀត បើតាមអ្វីដែលខ្ញុំពិនិត្យខ្ញុំ និយាយជាមួយតាចាយ ខ្ញុំក៏និយាយជាមួយ ខេង យើងថាទៅខាងមុខនេះ ឥឡូវយើងបណ្តុះបណ្តាលចេញពីសាលា-ភូមិន្ទរដ្ឋបាលមានក្មេងមួយចំនួន ហើយក៏មានមន្ត្រីមួយចំនួនក៏មានសមត្ថភាពមកពីអតីត FCP អតីត B.L.D.P ដែរ យកមកដាក់ក្នុងកន្ត្រកជាមួយគ្នាមកអារឿងនយោបាយជារឿងផ្សេង តែអារឿង Fontion Public គឺរឿងផ្សេង អញ្ចឹងខ្វះ១០ យក២០ យកមកធ្វើតេស្តរួចហើយយើងដាក់ទៅកុំទៅស្រែកពីរឿងបាត់ ឱ្យតែបាត់ធ្វើតេស្តដាក់២ គឺធ្វើជារបៀបបង្កើតអាហ្នឹងឱ្យបានបង្កើតនូវស្ថានភាពហ្នឹងឱ្យបាន ហើយឥឡូវដឹងទេថា ខ្ញុំកំពុងដកអាវុធទេ ? ដកសន្ទឹកសន្ធាប់ណាស់២ រួចអញ្ចេះ ឆ័យ ឯងចាំមើល បើស្តាប់ប្រជាពលរដ្ឋាអំពីវិធានការណ៍៨ចំណុច ដែលខ្ញុំបានដាក់ចេញនោះ ខ្ញុំមិននឹកស្មានថាអា៨ចំណុចដែលខ្ញុំប្រកាសទៅវាមានឥទ្ធិពលជ្រាលជ្រៅអញ្ចឹងទេ ហើយក្នុងអា ៨ចំណុចនេះ វាមានអាព្យា-ក្រិត្យភូបនីយ្យកម្មកំលាំងយោធានិងរដ្ឋបាលស៊ីវិល កុំឱ្យវាជាប់ពាក់ព័ន្ធ អញ្ចឹងបានកន្លងទៅធ្វើជាគំរូមួយមើល ឱ្យ ខូ ឈៀ ធ្វើប្រធានយោធភូមិភាគទី៥ ខ្ញុំគិតពីរឿងសមត្ថភាព អញ្ចឹងទេខ្ញុំសូមអង្វរអស់លោកតែម្តង ។

**សុន ឆ័យ:** ឥឡូវអញ្ចេះ ......មិនមែនការចរចាទេណា៎ ប៉ុន្តែយោបល់យើងត្រូវដោះគ្នាម៉េចនោះណា៎ យើងអាច

បាននូវបញ្ហាពា អាហ្នឹងយើងអាចធ្វើបានដើម្បីឱ្យគេត្រឡប់ទៅវិញបាន សូមឱ្យកងទ័ពអព្យាក្រិត្យ ។

**សម្ដេច** : អាហ្នឹងខ្ញុំទទួលស្គាល់ ។

**សុន ឆ័យ**: យើងរុញបន្ថែមទៀត ប៉ុន្តែគេថាអញ្ចេះ គេចង់រុញព្រះកូណា ដែល អី! ឱ្យមានអន្តរជាតិគេជួយយើងក្នុងពេលបោះឆ្នោតអីនោះណា៎ គេសាកឱ្យព្រះកូណាមើលនោះណ៎ គេសិក្សាអីចង់ឱ្យគេមើលនោះថាវាមិនទៅផេះទេ ប៉ូលីសអាព្យាក្រិត្យ យើងធ្វើឱ្យឃើញច្បាស់ប៉ូលីសអព្យាក្រិត្យ ហើយពីរឿងតម្រួតការពារយើងអត់មានទៅភ័យចំពោះកំលាំងនេះប៉ុន្មានទេ ។ ចំពោះកងកំលាំងអង្គរក្ស អង្គរក្សយើងនឹងពិនិត្យមើលឡើងវិញ យើងដាក់តែចំនួននេះហើយ ចំនួនយើងប៉ុន្មានថាជាការចាំបាច់ ហើយយើងធ្វើទៅចាំគេមកមើល អាហ្នឹងរបៀបយើងរៀបចំនោះណា៎ អាហ្នឹងជាចំណុចក្ដៅដែលគេចោទយើងថាមានអង្គរក្សច្រើនមានអីច្រើន ឥឡូវអព្យាក្រិត្យយ៉ាងម៉េចអីយ៉ាងម៉េច សូមលោកប្រាប់ភ្លាមមក ប៉ុន្តែពួកវាអស់ហ្នឹងទោះបីជាម៉េចក៏មិនទៅជឿទេ វាអព្យាក្រិត្យចំនួន ។

**សម្ដេច** : អាមេរិកាំងឈប់លើកហើយ អាហ្នឹងអាមេរិកាំងគេលើកអញ្ចេះ បើយើងរុញអាព្យាក្រិត្យបន័យ្យកម្មកំលាំងប្រដាប់អាវុធរួចហើយ ខ្ញុំបង្ហាញថាកំលាំងកងអង្គរក្សរបស់ខ្ញុំមានតែ៤០នាក់ទេ ក្រៅពីនោះ គឺជាកំលាំងកងយោធពលខេមរភូមិន្ទដែលគេចាត់មកការពារអីត្រង់ណា អាហ្នឹងរឿងរបស់គេទេ១ ហើយដែលហៅថាអង្គរក្សខ្ញុំគឺពួកស្លៀកពាក់ស៊ីវិល បើយើងពាក់អាវធំ វាពាក់អាវធំ បើយើងពាក់អាវតូច វាពាក់អាវតូចដែរ អាហ្នឹងបានហៅថាអង្គរក្ស ។

**សុន ឆ័យ**: ព្រះកូណាក៏,

**សម្ដេច** : អាហ្នឹងនៅក្នុងផ្ទះយើងនេះ ប៉ុន្តែថាដាក់ការពារជុំវិញប៉ុន្មាន ជារឿងរបស់អគ្គសេនាធិការទេ ប៉ុន្តែគេលើកមកអញ្ចេះវិញ ខ្ញុំក៏យល់ព្រមជាមួយអាមេរិកហើយ គេលើកថាសុំឱ្យគណបក្សនយោបាយមួយ១ឱ្យមានកំលាំងអង្គរក្ស ខ្ញុំថាឯកភាព ប៉ុន្តែកំលាំងអង្គរក្សនេះឱ្យអ្នកហ្នឹងរើស រួចហើយត្រូវឱទ្ទេសនាមឱ្យក្រសួងមហាផ្ទៃគេទទួលស្គាល់ ព្រោះយើងមិនអាចយកកំលាំងអង្គរក្សអីផ្សេងក្រៅពីមនុស្សដែលគេជិតស្និទការពារស្នាក់ការបក្សគេ ការពារឯកសារបក្សគេ សូម្បីតែស្រុកបារាំងក៏គេអនុញ្ញាតឱ្យបក្សកុម្មុយនីស្តបារាំងមានអង្គរក្សដែរ កាលពីខ្ញុំទៅឆ្នាំ៩៧ ពួកបក្សកុម្មុយនីស្តបារាំងគេមានអង្គរក្សរបស់បក្សកុម្មុយនីស្ត ប៉ុន្តែអង្គរក្សនោះត្រូវបានចុះបញ្ជីក្នុងក្រសួងមហាផ្ទៃ ហើយចំពោះកងទ័ពឬកងនគរបាលត្រូវផ្ដល់សេវា ផ្ដល់ឱ្យគ្រប់គណបក្សនយោបាយស្មើ១គ្នាដូច១គ្នា មួយគេជានាយករដ្ឋមន្ត្រី ឬក៏គេអគ្គ-សេនាធិការកងទ័ព ឬអគ្គសេនាធិការ រឿងរបស់គេមួយផ្សេង ប៉ុន្តែចំពោះគណបក្សនយោបាយគឺស្មើគ្នាអានេះខ្ញុំថាវាងាយធ្វើទេ ឱ្យតែយើងមានចិត្តស្មោះត្រង់នឹងធ្វើ ខ្ញុំថាធ្វើព្រោះបញ្ហាវានៅត្រង់ណេះ ជាក់ស្ដែងនៅឆ្នាំ៩២-៩៣ មានរឿង អាកាស៊ី មកនៅក្បែរ១ខ្ញុំដដែលហ្នឹង អញ្ចឹងឥឡូវខ្ញុំធ្វើការដោះស្រាយនៅក្នុងលើកនេះ រឿងលើកនេះ ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ខ្ញុំឃើញថាការទទួលខុសត្រូវរបស់ខ្ញុំខ្ពស់ហើយកាន់តែធំលើសពីសម័យអ៊ុនតាក់ ចុះបើសិនយុទ្ធនាការបោះឆ្នោតអន្តរជាតិចង់មក បើគេចង់មកឱ្យគេមក បើអ្នកឯងចង់មក ប៉ុន្តែទៅរួចហើយព្រោះអី? ព្រោះ...កុំឱ្យមាន ពីមុនយើងមានបំពាក់អាវុធ

កាលពី៩៤ មានបំពាក់រួចម្ដងឡើងវិញ ហើយផ្អាកម្ដងទៅហើយ ដល់ឆ្នាំ៩៤ សម្ដេចក្រុមព្រះបបួលខ្ញុំថាម៉េចមិនធ្វើតាមសម័យរដ្ឋកម្ពុជាបើខ្មែរក្រហមនៅច្រើន ខ្ញុំក៏បំពាក់ឡើងវិញទៅ ឥឡូវខ្ញុំគិតថានៅតំបន់សៀមរាបនៅតំបន់ខាងលើៗឯណោះ ប៉ុន្តែនៅតំបន់ក្បែរនេះកុំឱ្យមានកាំភ្លើងអត់ឱ្យមាន ជារួមខ្ញុំដកអស់រលីង ប៉ុន្តែនៅនេះគ្រាន់តែនៅជុំវិញក្រុងភ្នំពេញ ដកប្រហែលជាប៉ុន្មានខេត្តដែលនៅជុំវិញរដ្ឋធានីភ្នំពេញ ជំហានដំបូងដកប្រហែលជាមួយម៉ឺន ដកប៉ុន្មានខេត្តហ្នឹង ។ ដកជំហានទី១ ចំនួន៣៨.០០០ដើម ជំហានទី១ បើមិនដកទេរឿងច្រើនណាស់ ភ្លៀងក៏វាបាញ់ ខ្យល់ក៏វាបាញ់ វាហ្វូចាប់ចន្ទក៏វាបាញ់ ទេវតាចុះមកក៏វាបាញ់ ជួនកាលគ្នាវាតែបីនាក់ កាំភ្លើងមានមួយដើមទៅស្កាត់ផ្លូវគេលេងរឿងវាអញ្ចឹង វាគ្រោះថ្នាក់ណាស់ក្នុងពេលយុទ្ធនាការបោះឆ្នោត ពេលយុទ្ធនាការបោះឆ្នោត ឆ៎យ ឯងទៅមានអ្នកកាន់កាំភ្លើងការពារ និយាយទៅរាងក្លាហាន ដល់ខ្ញុំទៅអត់មានកាំភ្លើងការពារ និយាយទៅមិនសូវក្លាហាន ក៏ប៉ុន្តែដល់ ឆ៎យ ឯងមានមួយដើម ខ្ញុំមានមួយដើម សូមកុំភ្លេច សូម្បីប្រជាជនមិនមែនមានតែបក្សមួយទេ វាមានបក្សច្រើន មានអ្នកគាំទ្រ ឆ៎យ ឯង មានអ្នកគាំទ្រខ្ញុំ ចុះដល់យើងប៉ះគ្នាទៅបាញ់គ្នាទៅវាយ៉ាងម៉េច វាមិនរឿងរបស់យើង? អញ្ចឹងដកទៅវាល្អជាងទុក អាហ្នឹងយើងបានដើរមួយជំហានហើយ ហើយដើរលឿនទៀតរហូតដល់បងប្អូនខ្លះគាត់ភ័យ យីភ័យអីបើអត់មានខ្មែរក្រហមវាយផង ហ្នឹង! យើងទទួលបានមួយជំហានទៀត បើនិយាយសុិចកូឡូហ្ស៊ី គេធ្វើអាហ្នឹងហើយ អាមេរិកទៅជាមានរឿងអង្គរក្សហ្នឹង គេនិយាយមុនអារឿងព្រឹត្តិការណ៍ដល់ក្រោយព្រឹត្តិការណ៍បានខ្ញុំថាម៉េចអ្នកឯងនិយាយពីរឿងអង្គរក្ស អង្គរក្សខ្ញុំដែលគេកត់សំគាល់ជាអង្គរក្ស គឺជាកំលាំងដែលស្លៀកជាស៊ីវិល បានហៅថាអង្គរក្ស ដល់គេហៅកំលាំងការពាររដ្ឋធានីភ្នំពេញ កងពលរបស់អគ្គសេនាធិការ គេចែកគ្នាទៅការពារព្រះមហាក្សត្រ គេចែកគ្នាទៅការពារប្រធានមន្ទីរ គេចែកគ្នាទៅការពារនាយក-រដ្ឋមន្ត្រីទី១ ទៅការពារនាយករដ្ឋមន្ត្រីទី២ រឿងរបស់គេទេ គឺមិនមែនជារឿងរបស់យើងទេ អញ្ចឹងគឺគេមានដាក់នៅ អមជិតយើងអីនេះដើម្បីវាងាយនៅក្នុង អន្តរាគមន៍ជួយការពារចុះ ឧបមាថាជាក់ស្ដែងព្រឹត្តិការណ៍កាលពីខែកក្កដា ឆ្នាំ១៩៩៧ ពេលនោះចូលមកប្រើបមកចាប់ខ្ញុំយកទៅបាត់ទៅវាយ៉ាងម៉េច ឬគេកំទេចខ្ញុំទៅ វាមិនរលាយទាំងអស់ ធម្មតាអគ្គបញ្ជាការ ប៉ុន្តែបើសិនជាខ្ញុំអស់តួនាទីអ្នកហ្នឹងក៏ចេញពីខ្ញុំដែរ ទាំងអង្គរក្សទាំងអីគេមិនចេញពីយើង ចុះបើគេមិនចេញបានប្រាក់ខែពីណា? ក្រែងពួកហ្នឹងគេស៊ីប្រាក់ខែ រាជរដ្ឋាភិបាល ហើយរដ្ឋាភិបាលគេត្រូវដកកំលាំងទៅការពារអ្នកផ្សេងប៉ុន្តែបើសិនអ្នកឯងចូលប្រឡូកក្នុងយុទ្ធនាការបោះឆ្នោត ពេលចូលទៅឃោសនាបោះឆ្នោត អាហ្នឹងសេវាត្រូវតែស្មើៗគ្នាទាំងអស់ អញ្ចឹងយើងត្រូវធ្វើលើកនេះ យើងត្រូវធ្វើឱ្យល្អក្នុងការបោះឆ្នោតត្រូវមានបរិយាកាសស្មើៗគ្នាទាំងអស់ អញ្ចឹងទេមធ្យោបាយរបស់រដ្ឋកុំឱ្យមានការប្រើប្រាស់ដូចជា រថយន្តក្ដីជាសម្ភារៈ ប្រាក់កាស់អី កុំឱ្យមានការពាក់ព័ន្ធទៅនឹងបក្ស បក្សណាគឺបក្សហ្នឹង វិទ្យុ ទូរទស្សន៍បើថាផ្សាយ១៥នាទីនៅទូរទស្សន៍មួយ គឺថាឱ្យស្មើគ្នាទាំងអស់ ព្រោះអញ្ចេះបើយើងប្រើប្រាស់មធ្យោបាយវាហួសហេតុ ឬលើសចំនួនលើសគណបក្សដទៃ បើវាឈ្នះលទ្ធផលក៏ពុំសូវល្អដែរ និយាយឱ្យវាពិតទៅវាមិនសូវល្អទេ ដូចឈ្នះ ដូចតាមរបៀប FCP ឈ្នះលើគណបក្សដទៃក៏វាមិនមែនល្អ យកឈ្នោះ

ឱ្យខ្លួនឯងយកមកប្រើសំរាប់ខ្លួន វាមិនសូវល្អ ។

**សុន ឆ័យ** : ............ ពិភាក្សាឱ្យមានប្រសិទ្ធិភាពនិយាយឱ្យចំពីរឿងព្រឹត្តិការណ៍ណាំ ។

**សម្តេច** : ឥឡូវឮថាមានក្រុមតំណាងរាស្ត្រមួយក្រុមចំនួន២៩នាក់ ហើយអាចឈានដល់៣២នាក់ ក្នុង FCP ពួកគេកំពុងធ្វើម៉េច? ពិបាកណាស់ ឆ័យ អើយ មិនដឹងជាស្អី១ទេស្រុកយើង ។ ប៉ុន្តែអញ្ចេះបើមានគំនិតអីជួយសរសេរអីមក ឱ្យខ្ញុំអីបន្តិចបន្តួចមក គឺវាអញ្ចេះកន្លងទៅពុំសូវចង់ ឡើងនិយាយក្នុងទូរទស្សន៍អីទេដូចជាវាហត់វាហេវតែប៉ុន្មានថ្ងៃដែលខ្ញុំមិននៅហ្នឹងណាំ ពួកព្រោលចុះ កព្រោលឡើង វាមានអ្នកដែលគេឱ្យចេញមុខ វាមានអ្នកដែលចេញមុខច្រើនជាងគេ ប៉ុន្តែឥឡូវយើងដោះស្រាយបានល្អហើយ។ ប៉ុន្តែឥឡូវយើងដោះស្រាយបានជោគជ័យកុងត្រូលហើយ ប៉ុន្មានថ្ងៃនេះខ្ញុំកំពុងកព្រោលពន្ធដានេះឱ្យវាចូលមកដល់រដ្ឋ ចំណូលវាអត់សមហេតុផល ចំណូលវាកើនដែរ ប៉ុន្តែវាអត់កើនអត់សមទៅនឹងអ្វីដែល.

**សុន ឆ័យ** : ចំណូលតែវាអត់សមទៅនឹងសេវា ឧទាហរណ៍ ទំនិញចូលតាមខេត្ត........ នៅតាមក្រសួងណា.... គយធម្មតាទេណាំក្នុងមួយខែវាបើក ៥០០ ទៅ ១០០០ ។

**សម្តេច** : ហើយគយធម្មតា ៥០០ ទៅ ១០០០ ទៅហើយចុះអាធំមេវា ត្រូវយក ២០% មិនត្រូវឱ្យយក ៨០% ទេ ធ្វើអញ្ចឹងវាងាប់ហើយ ។ កន្លងទៅនេះកាលដែលសភាពការណ៍មុនពេលដែលខ្ញុំចេញទៅនេះ ខ្ញុំស្តាប់របាយការណ៍ខាងផ្នែកផ្សេង១ខ្លះបញ្ជាំងចេញមកបាត់ ក្នុងក៏វិតប្រហែល៥០%ដល់តំណាក់កាលពេលភ្ជុំនេះវាបាត់ស្មើតែ ៧០%ទៅហើយ ពេលមុនភ្ជុំទំនិញសំរុកចូលវាបែរជាចំណូលគយធ្លាក់ ហើយមិនដឹងថាវាលិខិត S.G.S ពីណាយកទៅយើងចាប់បាននៅភ្នំពេញ គ្រាន់តែម្សិលម្ងៃ និងម្សិលនេះ ចាប់បាន១៤កុងតឺន័រ ឥឡូវលេងដល់ឈើប្រភេទលេខមួយ ឈើប្រណិតដាក់ចេញតាមហ្នឹង ខ្ញុំថាដល់ចិត្តហ្នង ប៉ុន្តែកព្រោកអញ្ចឹងបន្តិចកន្លងទៅបងប្អូនយើងក៏អត់ចេះឈ្លើយដែរ ការពិតបើសន្មរកថាមានចរិកដដែល១ យកទៅចាក់ទាំងដុល១អស់រលីង ប៉ុន្តែយើងមិនចេញអីទេ ទូរទស្សន៍ខ្លះក៏អត់កាត់ វាកាត់ទៅ វាផ្សាយទៅធ្វើអត្ថធិប្បាយទៅ បើរឿងសំខាន់ចាក់ផ្សាយបួនដប់ម៉ាត់អាត្រង់ហ្នឹងទៅ អាហ្នឹងយកមកនេះខ្ចិល កាត់ចាក់ទាំងអស់វាច្រើនណាស់ បងប្អូនជូនកាលវាខ្ចិលវាដែរ វាមិនដឹងច្រិបត្រង់ណាអីត្រង់ណាទៅទៀតហ្នឹងណាំ ។

**សុន ឆ័យ** : តាមចិត្តរបស់ប្រជាពលរដ្ឋ.... ឃើញបងចេញអញ្ចឹងទៅបានចេះរៀបចំ ឃុំស្រុកយើងហ្នឹងជាពិសេសដូចសង់សាលា អ្នកខ្លះពេញចិត្តអ្នកខ្លះមិនពេញចិត្ត។

**សម្តេច** : វាមានអញ្ចឹងដែរ អញ្ចឹងហេតុអីបានខ្ញុំដាក់ចេញវិធានការណ៍ ៨ចំណុចនេះ បើសិនជាយើងមិនធ្វើអញ្ចឹងទេ ក្នុងថ្ងៃណាមួយយើងនឹងងាប់ខ្លួនឯងវិញ យើងធ្វើសាលារាប់រយខ្នង រាប់ពាន់រាប់ម៉ឺនខ្នងក៏ដោយ ក៏នៅទ្រាំមិនរួចនូវអំពើអាក្រក់ដែលប្អូនបានប្រព្រឹត្ត អញ្ចឹងទាស់តែដកពួកនោះចេញ ដកនឹងអីដកកាំងភ្លើងបណ្តោយ ដល់ដកកាំភ្លើងទៅវានៅសល់ដៃគ្រប់គ្នា អញ្ចឹងវាទៅរញ៉េរញ៉ៃទេ។

**សុន ឆ័យ** : យកចបទៅកាប់ដីទៅ ។

**សម្តេច** : យកចបទៅកាប់ដីទាំងអស់គ្នា បានវាអស់រឿងទាំងអស់គ្នា ប៉ុន្តែបើយើងបង្កើត អាព្យាក្រិត្យកងទ័ព

នគរបាលរដ្ឋបាល ហើយបង្កើតគណៈកម្មាធិការបោះឆ្នោតឯករាជ្យ ដើម្បីជាយន្តការអចិន្ត្រៃយ៍ អាហ្នឹងសំខាន់ណាស់បង្កើតយន្តការអចិន្ត្រៃយ៍ អាហ្នឹងមួយឱ្យបាន អាហ្នឹងវាគិតតែពីរឿងបោះឆ្នោតពីរឿងផលប្រយោជន៍ ព្រោះវាអចិន្ត្រៃយ៍ទៅហើយ បើយើង អាដហុក វាអត់ទៅរួចទេ អាដហុក បើខ្ញុំកាន់អំណាចទៅ ខ្ញុំរៀបចំតាមប្រមូលរបស់ខ្ញុំទៅ ឆ័យ ឯងកាន់អំណាចទៅ ឆ័យ ឯងធ្វើទៅអញ្ចឹងអញ្ចឹងបានឯករាជ្យ ទី៣ បានខ្ញុំរៀបចំឱ្យមានអង្គការសិទ្ធិមនុស្សដើម្បីឱ្យវាយក្បាលរដ្ឋាភិបាលឱ្យត្រង់ទិស យើងខាងលើចង់ធ្វើឱ្យល្អ ប៉ុន្តែខាងក្រោមវាមិននឹងអញ្ចឹង វាពួយច្រវ៉េងច្រវ៉ាងអញ្ចឹងទៅហើយដល់អញ្ចឹងយើងខំធ្វើអត់អស់ទេ ។

**សុន ឆ័យ**: អាហ្នឹងត្រឹមត្រូវហើយបង ខ្ញុំសូមជំរាបបងពីរឿងដូចជាការងារហ្វឹកហ្វឺន ហើយនិងកំលាំងបងហ្នឹងណាំបងឯងធ្វើតែឯង...អ្នកខ្លះចង់ជួយបង តែជួយបងទៅជាគ្រោះថ្នាក់ដល់បង វាធ្វើអត់សម ដល់វាធ្វើអត់សមទៅជាខូចតែម្តង ឧទាហរណ៍ថា រឿងករណី រស្ស៊ី ...ឥឡូវហ្នឹងវាទៅជាថាយើងជាអ្នកខុសទៅវិញ ពីព្រោះយើងបានយកវាទៅ ទៅចាប់វាអីហ្នឹង អត់អនុញ្ញាតយ៉ុអី ដូចជាអចិន្ត្រៃយ៍អី ចេះតែធ្វើទៅវាហួសពេលយ៉ុអីហ្នឹង ដល់តែធ្វើអញ្ចឹងទៅ វាអត់របៀប... ធ្វើទៅឱ្យវាទៅតាមរូបមន្តវាអត់អីទេឧត្តមគតិនយោបាយ.... ដល់អញ្ចឹងខ្ញុំធ្វើការនេះឱ្យវាទៅតាមរកចំនុចអត់ឃើញទេ ពុំអាចបន្ទោសវាបាន អត់មានរឿង បានថាធ្វើការ ខ្ញុំធ្វើឱ្យតែបងឯងមួយទេ .......ដល់ហើយទៅជារូបភាពជាក្រុមយល់ការងារហើយអត់ពិបាកឆ្ងល់ទេ អត់ពិបាកអ្នកឯងទុកចិត្ត ឬមិនទុកចិត្តទេ ប៉ុន្តែគ្រាន់តែអ្នកឯងធ្វើអាហ្នឹងគឺថាប្រាប់ទៅ គឺថាយកទៅដូចខ្ញុំជំរាប ។

**សម្តេច** : ប៉ុន្តែសភាពការណ៍ចុងក្រោយនេះដូចរាងធូរបន្តិច អាក្រោយព្រឹត្តិការណ៍នោះណាំ ធូរបន្តិច លើសភាពការណ៍យោធា សន្តិសុខស្អី១ហ្នឹងឃើញមានដាក់ទ័ពដូចជាជុំជើងគ្នាទៅ ទា ចំរ៉ាត់, ទៀ បាញ់គេនៅជាមួយគ្នាស្អី១អញ្ចឹងទៅ វាដូចជារបៀបដោះអញ្ចឹងទៅវាបានស្រាលបន្តិច ។

**សុន ឆ័យ**: វាស្រាយហើយ ប៉ុន្តែអញ្ចេះពីមុនមកវាឃើញសភាពមេ១ទេ ដែលវាបានសប្បាយចិត្ត អាកូនកើតទុក្ខនោះ អាកូនវាឈឺអត់មានអ្នកមើល នេះហើយដែលខ្ញុំនិយាយថា ឧទាហរណ៍ឥឡូវទាហានលោកឯងមានតែ៣០០ទេ ខ្ញុំដឹង តែអ្នកឯងស៊ីលុយ ១០០០នាក់ ប៉ុន្តែអ្នកឯងកុំលេបទាំង ៧០០ នោះណាំយកត្រឹម ២០០ ទៅអា ៥០០ ដែលលើសនោះយកចិញ្ចឹមវាផង ថែមឱ្យវាទៅ ព្យាបាលឱ្យវាទាំងអស់ហ្នឹង ឱ្យវាសប្បាយចិត្តទាំង៣០០ ហ្នឹង គេអត់ធ្វើអញ្ចឹងតាំងពីដើមមក គឺវាអញ្ចឹង....កាលពី៩២-៩៣ ខ្ញុំឃើញគណបក្សប្រជាជនទិញម៉ូតូឱ្យ.:.. កុំឱ្យវាមិនច្បាស់ ឱ្យវាធ្វើឱ្យវាច្បាស់ក្នុងការងារហ្នឹង ខ្ញុំឃើញមានរឿងច្រើនណាស់បង ហើយទាក់ទងនឹងរឿងប៉ូលីសខ្លាចខ្ញុំ វាដឹងខ្ញុំប្អូនបងខ្ញុំទៅវាខ្លាចខ្ញុំ....។

**សម្តេច** : កន្លងទៅគណបក្សប្រជាជនត្រូវដកពិសោធន៍ លើកនេះយុទ្ធនាការបោះឆ្នោតឬក៏ស្អី១ គឺអត់មានតែម្តងសុខចិត្តយើងទៅដល់កន្លែងគាត់ជាជាងនាំគ្នាមកប្រមូលមួយដុំមក រួចហើយអាមកត្រូវមកដេកចាំយើងទៅវិញអត់បាយ ដើរម្តាយបណ្តោយ ។

**សុន ឆ័យ**: មិនហៅក៏គាត់បោះឆ្នោតឱ្យ ។

**សម្តេច** : បាទ! អ្នកមិនហៅរូចហើយយើងសុខចិត្តយកវីដេអូ យកកាសែតអីឱ្យគាត់មើលវាសមរម្យផង។

**សុន ឆ័យ** : គេទៅស្វាយរៀង២យប់តើ បានហើយឯកឧត្តម ទៀ បាញ់ គាត់ហៅមកទាំងហ្វូងមកគឺគាត់...... ខ្ញុំស្នើកប្រជុំចុះទៅ ល្អហើយចុះយុទ្ធនាការអញ្ចឹង បើកុំចុះយុទ្ធនាការយើងមិនអាច ។

**សម្តេច** : សៀវភៅ២ក្បាល ទាំង២ ឆ័យ ឯងយកទៅមើលអានេះ ។

**សុន ឆ័យ** : ខ្ញុំបកយកមកជូនបងវិញអញ្ចឹង ?

**សម្តេច** : អត់ទេ ឆ័យ ឯងយកទៅ តែអានេះមិនទាំងចងសួរ ចងសួរចំលើយមនុស្ស ៤នាក់ហ្នឹង ។

**សុន ឆ័យ** : អានេះមាន គៀង ភ័ង គៀង ភ័ង អី?

**សម្តេច** : អើ! មានទាំង គៀង ភ័ង អីហ្នឹងហើយ ។

**សុន ឆ័យ** : ខ្ញុំមកជំរាបសួរអញ្ចេះផង ខ្ញុំប្រាប់ជូនដំណឹងខ្លះក្រែងលោមានរឿងកើតមកអំពីបញ្ហាគេស្នើគេអីហ្នឹង ខ្ញុំទៅវិញ ទៅអូស្ត្រាលី ព្រោះថាខ្ញុំមកហ្នឹង ខ្ញុំចូលកាន់ក្រសួងស៊ីវិលនៅអាផ្ទះការប្រជាធិបតេយ្យហ្នឹង ខ្ញុំនៅហ្នឹង ដល់ខ្ញុំចេញមកគេប្រទាញប្រទង់ ថាខ្ញុំនឹងមករកបងអីអញ្ចឹងទៅ ហើយខ្ញុំបានថាខ្ញុំអត់នៅ ខ្ញុំចេញទៅវិញ ខ្ញុំទៅអូស្ត្រាលី ប៉ុន្តែដល់ខ្ញុំមកវិញ ខ្ញុំមកនៅហ្នឹងជាមួយបង ថាច់ ប៉ែន ជំរាប់បងឱ្យដឹង។

**សម្តេច** : ប៉ុន្តែឥឡូវហ្នឹងនៅប៉ុន្មានថ្ងៃចូលប្រជុំសភា ទៅបានឃើញមុខបន្តិចទៅ ?

**សុន ឆ័យ** : សម្តេច សភាសុំជួបលោកថា ចាំមកថ្ងៃច័ន្ទមកជួបព្រឹកទៅចូលមកឱ្យគេឃើញមុខ សុន ឆ័យ បន្តិចទៅ ហើយខ្ញុំបាននិយាយប្រាប់សភាអញ្ចេះ ដើម្បីឱ្យយល់ចិត្តគ្នាតែម្តង ខ្ញុំចង់ឱ្យឃើញការសុំឱ្យតំណាងរាស្ត្រចូលមកដើម្បីបំភ្លឺរឿងច្បាប់បោះឆ្នោត ព្រោះអញ្ចេះខ្ញុំទៅវិញខ្ញុំទៅបាងកក ខ្ញុំទៅនិយាយជាមួយតំណាងខាងណោះ មិនដឹងជាបានមិនបានខ្ញុំមិនហ៊ានធានាទេ ប៉ុន្តែខ្ញុំអាចនិយាយទំនងគេស្តាប់បានខ្លះពីបញ្ហាខាងក្នុង បានខ្ញុំបោះបង់ហើយ ខ្ញុំអត់នៅជាមួយអ្នកឯងទៀតទេ ខ្ញុំដាក់ពាក្យវិញហើយ ខ្ញុំទៅអូស្ត្រាលីហើយ ចប់រឿងហើយ ខ្ញុំមកពីណោះវិញ។ ដូច្នេះខ្ញុំបាននិយាយថា ខ្ញុំមកនេះខ្ញុំមកមើលសភាពការណ៍ស្រុកខ្មែរ ខ្ញុំនឹងមិនចូលប្រជុំសភាទេ និយាយជាមួយកាសែតពីព្រឹកម៉ិញមុននឹងមកហ្នឹង ដូច្នេះបើសិនណាត្រូវចូលប្រជុំសភា ប្រហែលជាចូល ចាំមើលបន្តិចទៀតសិន មិនទាន់សំរេចទេ។

**សម្តេច** : ចូល ចូលជួបប្រធាន ។

**សុន ឆ័យ** : បាទ! ...... ប៉ុន្តែបងមានប្រសាសន៍អញ្ចឹងគោលការណ៍....អ្នកភ័យ ឱ្យវាមក១...។

**សម្តេច** : អត់ទេ! ថ្ងៃមុនមានខាងណោះមកសួរដូចថា អារឿងដាក់គុកដាក់អី ខ្ញុំថាទេកុំអាលគិតអញ្ចឹង ព្រោះអ្នកទាំងនេះនៅនិយាយគ្នាបាន ប៉ុន្តែ ប៉ោ ប៊ុនស្រ៊ី ប្រហែលមិនមកទេ ។ ប៉ោ ប៊ុនស្រ៊ី មកទាល់តែអាមេរិកបញ្ជូនមក ព្រោះមានករណី ១៥នាក់ ។ នេះក្នុងចំណោម៤១ករណី វាមានមួយចំនួនអាចដឹងអត្តសញ្ញាណតែម្តង ប៉ុន្តែក្នុង៤១ករណីនេះ ក៏មានមួយចំនួនកំពុងនៅរស់ អ្នកដែលគេសង្ស័យថាស្លាប់ហ្នឹងណាំ ប៉ុន្តែឥឡូវដូចករណីកំពង់ស្ពឺអី ។

**សុន ឆ័យ** : អត់រកឃើញមនុស្សម្នាក់ វាខូចការដែលយើងនិយាយហ្នឹង ។

**សម្តេច** : ចុះពួកហ្នឹងចូលធ្វើការហើយ អញ្ចឹងទេ ៤១ករណីនេះ មានអ្នកខ្លះដែលមិនស្គាល់អត្តសញ្ញាណហ្នឹង គឺអាចនិងពួកជាក្រុមអន្លង់វែងឬក៏ក្រុមរបស់ នួន ប៉ែត ព្រោះថ្ងៃដែលប្រយុទ្ធហ្នឹង នួន ប៉ែត នៅផ្ទាល់។

**សុន ឆ័យ** : ចុះ ជា ឈុត យ៉ាងម៉េច ?

**សម្តេច** : ជា ឈុត មកប្រហែលជាមួយអាទិត្យក្រោយព្រឹត្តិការណ៍ពេលដែលបង ទា ចំរ៉ាត់ មកដល់នេះវិញ បង ទា ចំរ៉ាត់ ដូចជាមកថ្ងៃម្តេចប៉ុន្មាន ពេលដែលបង ទា ចំរ៉ាត់ មកនេះ គឺគាត់ថាទាក់ទងបង ជា ឈុត ហើយដល់អញ្ចឹងតាំងពីពេលហ្នឹងមកបាត់ខ្លួនគាត់ ព្រឹកម្សិលក៏មិនបានសួរគាត់ថាយ៉ាងម៉េច ប៉ុន្តែពេលដែលមកដល់ដំបូងគាត់ថា ទាក់ទងបាន រួចបានមករាយការណ៍ឱ្យខ្ញុំ ខ្ញុំថាឱ្យបង ចំរ៉ាត់ ទាក់ទងយកមក បង ទេព នន្ទារី នៅហ្នឹង ហើយបង ថាច់ ឃន មកជួបខ្ញុំនេះហើយ និយាយរួម ចៅហ្វាយខេត្តបាត់តែមួយទេ បាត់តែ ទេព នន្ទារី ទេ រួចទៅទាញយកមកបាន ។

**សុន ឆ័យ** : ទេព នន្ទារី ឃើញនៅជួបនៅបាងកក ហើយចៅហ្វាយខេត្តរងកោះកុង ដែលរត់មកគណបក្សប្រជាជនវិញ ប៉ាល់ សាន  ប៉ាល់ សាន ឃើញ ។

**សម្តេច** : ហ្នឹងហើយ ប៉ាល់ សាន, ជែន សុឃុល បែបជានៅម្តុំអារញ្ញអីហ្នឹងទេ ហើយនិង ហង្ស យុទ្ធ ហើយក្រៅពីហ្នឹងគឺ ថាច់ ឃន គាត់នៅ ថាច់ ឃន ខ្ញុំឱ្យទៅយកមក ហើយម្នាក់នៅក្នុងហ្នឹង នៅពេលដែលអង្គុយជុំគ្នា គៀង វ៉ាង, យូ ហុកគ្រី លី ធុច, ហូ សុខ ដែលកំពុងអង្គុយបញ្ហាលើភ្លិបហ្នឹង ដែលពាក់ផ្កាយមួយ គឺមកហើយ ឥឡូវហ្នឹងគឺ ថាឱ្យទៅកាន់អនុភូមិភាគ២ ហើយផ្ទេរអនុភូមិភាគ២ ឱ្យមកកាន់អនុភូមិភាគពិសេស ហើយចាំមើលបង គួ ឈាន ក៏គាត់ទទួលយក ប៉ុន្តែគិតឱ្យបង ឃួន រឿន, បង ឃួន រឿន របួស ។

**សុន ឆ័យ** : ហ្នឹងហើយឮថាស្លាប់ ខ្លះឮថារបួស ។

**សម្តេច** : ហ្នឹងហើយរបួសនៅហ្នឹងផ្ទះ បង ក្រូច យឿម ត្រូវគេក្លុងយកទៅទៀតណាំ គាត់នៅហ្នឹងទូរស័ព្ទដល់ទូរស័ព្ទមកខ្ញុំឱ្យមនុស្សភ្លាមយកទៅដាក់ពេទ្យ ដល់ដាក់ពេទ្យគាត់ទូរស័ព្ទទៅរកប្រពន្ធគាត់ ដល់ទូរស័ព្ទទៅរកប្រពន្ធគាត់ អ្នកនៅជាមួយខាងប្រពន្ធគាត់ថា មុខជាគេគំរាមហើយ គំរាមឱ្យគាត់និយាយហើយ បានប្រពន្ធគាត់មកដល់ជួបគាត់ ព្រោះយកទៅដក់ពេទ្យឱ្យបន្ទប់មួយតែម្នាក់ឯង ហើយការពារឱ្យហ្មត់ចត់នៅតែពីរនាក់ប្តីប្រពន្ធហ្នឹង ដល់ជាហើយមកបាយជាមួយខ្ញុំហ្នឹង មកពីរដងជាមួយខ្ញុំហ្នឹង ហើយដល់ថ្ងៃ ហាំ ម៉ាប៊ីក ជួបខ្ញុំ ខ្ញុំហៅឧត្តមសេនីយ៍ ៥នាក់ និងវរៈសេនីយ៍ឯក ៥នាក់ ដែលគេសង្ស័យថាស្លាប់ហើយនោះ មកនៅអង្គុយហ្នឹងទាំងអស់គ្នា ខ្ញុំថានែ៎ ម្នាក់នេះ ឃួន រឿន ខ្ញុំឱ្យអង្គុយត្រង់ហ្នឹង ដល់ហើយខ្ញុំថា ម្នាក់នេះរបួសជើង ហើយយកទៅពេទ្យហើយចេញពីពេទ្យ គេកំពុងតែពាក់ផ្កាយរបស់គេ អញ្ចឹងគឺយើងមិនត្រូវការជំទាស់អីជាមួយអ្នកទាំងនោះទេ ។ ខ្ញុំនិយាយឱ្យសច្ចៈយុត្តិធម៌ បើកុំបានអ្នកទាំងនេះលូកដៃមកជួយយើង ហើយអ្នកនេះបែជារត់ដែរ ក្រុមសិទ្ធិមនុស្សក៏រត់ ក្រុមសិទ្ធិមនុស្សបរទេសដែរ យើងមិនអន្តរធាន មិនពិបាកនរណាធ្វើសាក្សីឱ្យយើង បានគេហ្នឹងហើយ អញ្ចឹងគឺថាអ្នកឯងចង់ទៅណានាំទៅហ្នឹង អញ្ចឹងបានឥឡូវយើងសួរតែប៉ុណ្ណោះ សួរថាម៉េចបានអ្នកហ្នឹង

ទៅរកគាស់ខ្មោចបាន ? បើសិនជាគេមានបំណងបិទដូចជាពួក សុចិន្ដា គាត់ធ្វើឆ្នាំ៩២នៅបាងកក ឬក៏ដូចជាករណីនៅទីម៉ូរខាងកើតដែរនោះ ម៉េចបានជាពួកហ្នុងដល់ពេលហ្នឹងទៅគាស់ខ្មោចបាន យើងដាក់តែប៉ុណ្ណឹង ដោយសារតែយើងមានចេតនាល្អ អ្នកឯងសង្ស័យត្រង់ណា ខ្ញុំជូនទៅត្រង់ហ្នឹង ហើយជូនទៅត្រង់ហ្នឹងជួយគាស់ខ្មោចទៀត ។

**សុន ន័យ**: ហើយអ្នកឯងមកចោទគេម៉េច ?

**សម្តេច** : ហើយអ្នកឯងធ្វើម៉េច? ព្រោះយើងក៏ចង់រកដែរ អ្នកណាក៏គិតអញ្ចឹង អញ្ចឹងបានខ្ញុំសូមជំរាបថាមិនមែនដាក់គុកអ្នកឯងមួយខែ ពីរខែ វាអត់មានច្បាប់សំរេចដាក់ទេ តែចាប់ហើយត្រូវចោទប្រកាន់ហើយមិនអញ្ចឹង តែចោទប្រកាន់ហើយគឺថា អាហ្នឹងឱ្យកាត់ទៅតាមច្បាប់តែម្តងបានល្អ អញ្ចឹងបានជាខ្ញុំថារឿងដែលគួរឱ្យសោកស្តាយ ហើយអ្វីដែលមិនគួរឱ្យកើតមាន ស្តាយបំផុត ស្តាយសម្តេចក្រុមព្រះលោកជឿមនុស្សពានាក់ហ្នឹង ជឿខុសហើយ ឃើញអត្ថបទព្រះករុណាឬនៅ ? មើលរស្មីកម្ពុជា ។

**សុន ន័យ**: ព្រឹកមិញនេះ ?

**សម្តេច** : អត់ទេ! ថ្ងៃមុនលោកសរសេរវិភាគពីពួករាជានិយមមិនមែន សីហនុ ។

**សុន ន័យ**: រាជានិយមដែរ តែមិនមែន សីហនុ និយម ?

**សម្តេច** : មិនមែន សីហនុ និយម មើលអាហ្នុងលោកសរសេរដែលដាក់ឈ្មោះ ឱម មុន្នី អីនោះពីមុនលោកដាក់រូបរិទ្ធ ប៉ុន្តែអានេះមិនមែនទេ ឥឡូវមើលក្នុងរស្មីកម្ពុជានៅថ្ងៃទី១១ ទំព័រទី១១លោកសរសេរជាបារាំងប៉ុន្តែគេបក លោកនិយាយពិតនិយាយត្រង់ ហើយខ្ញុំមិននឹកស្មានទេ ហើយឥឡូវនេះវាបាត់អាជាននេះមួយ ឥឡូវខ្ញុំយកបានអាកាស៊ីឡង់ហ្ស៊ី៤. អាកាស៊ីឡង់ហ្ស៊ី១បានបាញ់រួចម្តងហើយ តែយើងអត់ដឹងបាញ់ខ្ញុំនៅស្រុកបូរីជលសា ។

**សុន ន័យ**: ចុះណែ! អង្គរក្សត្រូវរបួស ។

**សម្តេច** : អត់ទេ អាហ្នឹងក្រោយទេ អាហ្នឹងយកអត់បានទេ អាវុធយើងយកអត់បានទេ។ អាហ្នឹងគឺគេដាក់នៅឯអីនោះ គឺសំរាប់ឱ្យបាញ់ខ្ញុំហ្នឹងគឺតាំងពីជំនាន់ សេរីវុឌ្ឍ. សេរីវុឌ្ឍ បំពាក់ ឥឡូវយកបានហើយ គេបាញ់ខ្ញុំហ្នឹងគឺថាកាលហ្នុងគេបាញ់ចំងាយ ៧០០ម៉ែត្រ ហើយខ្ញុំកំពុងឈរថ្លែងការណ៍នៅវាលស្រែហ្នុង ហើយបាញ់ ៧០០ម៉ែត្រ បាញ់ម៉េចត្រូវ បើស៊ីឡង់ហ្ស៊ីធ្វើម៉េចឮ ឯយើងវាអត់ឮពេលហ្នុង ។

**សុន ន័យ**: ទៅធ្លាក់ឯណាអីណោះទៅ ។

**សម្តេច** : ធ្លាក់ឯណាទៅឯណានោះទៅ ហើយបាញ់ខ្ញុំនៅតាកែវ បាញ់នៅព្រៃកប្បាស់ បាញ់នៅអង្គរបូរី បាញ់នេះបាញ់នៅបូរីជលសា រួចហើយអាមួយដើមដែលបាញ់ខ្ញុំនៅនេះ ឥឡូវហ្នឹងបាត់មនុស្សហ្នឹង គ្នាគឺជាអ្នកដែលបានទទួលបញ្ជាឱ្យមកបាញ់ ប៉ុន្តែមិនមែនអ្នកដៃដល់ទេ ប៉ុន្តែរួចហើយបានមកទំនាក់ទំនងជាមួយយើង ដល់អញ្ចឹងយើងវាមានភាពបន្ទាន់ដើម្បីទៅចាប់ អាស្មឹងហ្គី អាស្មឹងហ្គីចូលមក ដល់ចូលមកហ្នឹងត្រូវយកតាមក្បួនឡានស៊ីម៉ងត៍ គឺថាមានប្រហែលជាជិត១០ឡាន អញ្ចឹងគេនឹងដាក់ក្នុងឡានមួយ៥ដើម។ អញ្ចឹងយើងត្រូវបញ្ជូនមនុស្សហ្នឹង ខ្ញុំឱ្យ២០០០ដុល្លារទៅដើម្បីឱ្យត្រឡប់ទៅវិញ រួចហើយឱ្យសញ្ញាដើម្បី

យើងស្ទាក់ចាប់នៅម្តុំកំពង់ត្រឡាចចន្លោះកំពង់ឆ្នាំងប្រើឱ្យទៅយកអាស្ទីងហ្គិ ដែលគេដាក់តាមឡានមក សំរាប់បំផ្លាញឧទ្ធម្ភាគចក្រខ្ញុំនេះ ដល់អញ្ចឹងខ្ញុំទៅក៏ជួបអាព្រឹត្តិការណ៍ហ្នឹង អញ្ចឹងអត់បានយកអានេះយក មក អញ្ចឹងអាដែលយកមកនេះ គឺយកមកមិនមែននេះទេ អាកាំភ្លើងដែលបាញ់ពីនេះទៅ វាបាញ់រួច វាចុះទឹក ដែលត្រូវអង្គរក្សនោះ ហើយថ្ងៃហ្នឹងយើងវាស់មើល គឺយើងសំណាងបន្តិចតែប៉ុណ្ណោះទេ ត្រង់ថាខ្ញុំចេញផុតពីវត្តនិរោធន៍ទៅពីត្រង់ព្រះនរាយណ៍ ទូរស័ព្ទពីចំការមនថាឱ្យខ្ញុំទៅដល់មុន ៣នាទី អញ្ចឹងខ្ញុំត្រូវឱ្យបើកតំហុគ ដល់បើកតំហុគទៅបានបន្តិច គឺបាញ់បណ្តោយ បាញ់ហើយវាចុះទឹក អញ្ចឹង បងប្អូនឆោឡោភ្ញាក់ប្រកាសអាសន្នភ្លាម ដោយកំលាំងអន្តរាគមន៍ទៅពីក្រោយ ។

**សុន ឆ័យ** : ចាប់បាន ?

**សម្តេច** : អត់ចាប់បានទេ ទៅរួច រួចវាទៅនិយាយនៅក្បែរតំណាក់ក្រុមព្រះហ្នឹង ពួកហ្នឹង គឺពួក សេរី កុសល វាថាអាខ្វក់ហ្នឹងបាញ់វាមិនត្រូវ អញ្ចឹងអាកាស៊ីឡង់ហ្ស៊ីហ្នឹង ម្នាក់ហ្នឹងត្រូវទុកហើយចាំតែត្រឡប់ពីយក អាវុធនោះមកវិញទៅយកអាកាស៊ីឡង់ហ្ស៊ី និងចាប់មនុស្សហ្នឹងមកឱ្យយើង ប៉ុន្តែចៃដន្យបាត់មនុស្សហ្នឹង ទៅ តែយើងអត់ដឹង អត់ដឹងទេថាមនុស្សហ្នឹងកំពុងនៅឯណាទេរាល់ថ្ងៃនេះ ប៉ុន្តែបើតាមការស៊ើបសួរ ពេលដែលយើងឱ្យមនុស្សយើងទៅយក Pilot ៤នាក់ ដែលខ្មែរក្រហមចាប់នៅអន្លង់វែង ហើយដែល បញ្ជូនចេញមកតាមអូស្មាច់នេះ ថាមនុស្សហ្នឹងគឺនៅឯហ្នុងនៅជាមួយ និន ពិន. និន ពិន មិនទាន់ ស្លាប់ទេ ព្រោះថារស់ ៥នាក់ហ្នឹង ក្នុងចំណោមប៉ុន្មានជាង១០នាក់ហ្នឹង ។ ប៉ុន្តែកូនចៅសុខសប្បាយ អត់អីទេ ?

**សុន ឆ័យ** : អត់អីទេ ប៉ុន្តែវាពិបាក ......។

**សម្តេច** : ប៉ុន្តែនៅឯណាឥឡូវ ?

**សុន ឆ័យ** : នៅផ្ទះខ្ញុំទួលគោកនេះ....។

**សម្តេច** : អើ មើលត្រង់ណាឱ្យវាសុវត្ថភាពបន្តិច ដើម្បីកុំឱ្យវា...................... ឥឡូវ អ្នកឯងចង់និយាយ ពីបញ្ហាព្រំដែនវាអត់ខុសគ្នាទេ ខ្ញុំក៏ចង់បានដែរ ខ្ញុំគាំទ្រអ្នកឯងឱ្យអ្នកឯងវាដោះស្រាយព្រំដែនឱ្យតែ អ្នកឯងដោះស្រាយបានល្អលើសខ្ញុំអាហ្នឹង ខ្ញុំសរសើរអ្នកឯងទៅវិញ បញ្ហាអន្តោប្រវេសន៍ខុសច្បាប់ ខុសស្អីឱ្យតែអ្នកឯងដោះស្រាយបានអញ្ចេះ កុំឱ្យតែអាយើងត្រូវបញ្ជូនទៅដល់ជ្រៃធំ....អញ្ចឹង រួច កម្មវិធីកសិកម្ម កម្មវិធីសេដ្ឋកិច្ចសង្គម វាអត់ឃើញអីខុសគ្នា ខ្ញុំអត់ឃើញអីខុសគ្នា អញ្ចឹងបញ្ហាដែល ខុសគ្នារវាង រណប្ញទ្ធិ និងគណបក្សប្រជាជន ផលប្រយោជន៍ធំអនុវត្តទៅចុងក្រោយ យកខ្មែរក្រហម មកលេងអាហ្នឹងអត់បានទេ ....អ្នកដែលវៃ គឺកំលាំងអា ប៉ែត ឥឡូវនេះយើងទប់ទល់ បានឱ្យ ចាប់យក នួន ប៉ែត ដើម្បីយកធ្វើសាក្សី ម្យ៉ាងកាត់ទោស ប៉ុន្តែឱ្យកាត់ទោសធ្វើសាក្សីមួយដែរ.... (១នាទី១៥វិនាទី) នៅពេលដែលយើងចាប់ផ្តើមសង្ស៊ឹមខ្លាំង កំលាំងរដ្ឋាភិបាលដែលទ្រទ្រង់ឱ្យចលនា ប៉ៃលិន និងម៉ាឡៃទៀតនោះ យើងនឹងចាប់ផ្តើមអនុវត្តពី.... ដល់ចាប់ផ្តើមឱ្យចូលរួបរួមជាតិ កំលាំង យើងក៏រុញឡើងនៅក្នុងរបស់ សុន សេន នៅក្បែរនេះមួយទៀត ក៏ផុសឡើងមួយទៀត ដល់ផុត

ឡើងមួយទៀត យើងដេញតា ម៉ុក ដេញ សុន សេន ចេញហើយ ក៏នៅសល់នាយ កន នៅហ្នឹង ហើយនាយ កន ហ្នឹងក៏ត្រូវចាត់មនុស្សទៅចរចាជាមួយនឹង អ៊ី ឈាន ទៅដល់ អ៊ី ឈាន ក៏ចាប់ដាក់គុកនៅហ្នុងទៅ រឿងវាអញ្ចេះ ដល់ពេលយើងធ្វើសមាហរណកម្មមក ដល់ពេលយើងដោះចេញពីមន្ទីរឃុំឃាំង គឺតា មុត កូនប្រសារតា ម៉ុក ..... ឥឡូវគេសំរួលវិញហើយនៅតែតា ម៉ុក ទេ។ កូនប្រសារតា ម៉ុក ហ្នឹងទៅជាមួយ ញឹក ប៊ុនឆៃ យើងក៏ដឹងដែរ ពេលចាប់ផ្ដើមតា មុត ជាកូនប្រសារតា ម៉ុក អញ្ចឹងនៅពេលមានធ្វើការតា ម៉ុក ក៏ក្រឡុកនៅសំឡូត វាក៏កើតមានបញ្ហានៅសំឡូតចន្លោះ.......ហើយដោយទៅហ្នឹងគឺ.......... តា ម៉ុក ហ្នឹង ហើយនិង...អ្នកទាំងនេះ ... អៀង សារី ចាប់ដាក់គុក ប៉ុន្តែនាយ កន គាត់មិនទៅទេ ដោយសារតែពួកតា ម៉ុក បានសំលាប់បងប្រុសរបស់គាត់ទៅហើយ អញ្ចឹងឥឡូវ អៀង សារី គាត់ក៏អត់ដែរ ៦ អ៊ី ឈាន កំពុងតែរួមកំលាំងទៅជួយដោះស្រាយសមរភូមិក្រោយ ពួកហ្នឹងគេអត់ទៅ...... កន្លងទៅហ្នឹងគឺឡើងដល់ហើយ ប៉ុន្តែភ្លៀងធ្លាក់ធំពេកបាត់បងប្អូន ឥឡូវរកសពអត់ទាន់ឃើញ៣នាក់នៅអូរស្មាច់ បើអញ្ចឹងគឺធ្លាក់មកតាមច្រកអូរស្មាច់ តាមការពិតយើងកាន់កាប់តើ ប៉ុន្តែអូរស្មាច់វានៅម្ដុំហ្នឹង ហៅកងទ័ព ...មិនមែនកងទ័ព FCP ទេ កងទ័ពរបស់ឧទ្ទាម... រួចហើយក៏ ម្លោះហើយបាញ់ម្ដងម្កាលដើម្បីថតរូប អញ្ចឹង កូហ្វីអាណាន់ សួរថាពួកនេះបាញ់ណា ? អត់ដឹងខ្លួនថាពួកហ្នឹង ខ្ញុំថាកងទ័ពខ្មែរក្រហមតើ មិនឃើញ រណឫទ្ធិ ប្រកាសថាអត់មានខ្មែរក្រហមទៀតទេ ព្រោះខ្មែរក្រហមបានធ្វើសមាហរណកម្មមកក្នុងកំលាំងរបស់លោកអស់ហើយ ហើយដល់នៅកន្លែងនេះយើងឡើងទៅដំណោះស្រាយនៅសល់តែប៉ុណ្ណឹង ដល់ភ្លៀងធ្លាក់គ្រឹបអញ្ចឹង យើងបង្ខំបង ប្អូនឱ្យឡើងអាលើចំណុចទួល ប៉ុន្តែប៉ុន្មានថ្ងៃនេះឃើញបងប្អូន ឈាន គាត់ក៏ប្រឹងណាស់ដែរ អ្ហ៎! ឈាន ដាក់ទៅម៉ឹងហ្នុង ថ្ងៃមុនខ្ញុំនិង យ៉ាន ខ្ញុំមកភ្លាមស្ដាប់របាយការណ៍ យ៉ាន. បាញ់. មាស សុភា .... ឈា គេរាយការណ៍មកថាឡោមព័ទ្ធពីខាងណាណោះមកហើយ ប៉ុន្តែវាខ្ពស់ពេក បានខ្ញុំថា អើកុំបង្ខំពេក ។ .......... ឡាយ វីរៈ គេរុញកំលាំងមកវ៉ៃ ......... ក៏កើតរឿងអញ្ចឹងទៅ ប៉ុន្តែដោយសារតែកន្លងហ្នឹងវាស្រួលបងប្អូនគេត្រឡប់មកវិញឯអូរស្មាច់នេះ ពីមុនថាបក្សពួក រណឫទ្ធិ គេចង់ចូល ..... អញ្ចឹងបងប្អូនក៏ចាប់ផ្ដើមរុញទៅ ...... កំរៀងតំបន់មួយចំនួនឱ្យបងប្អូនមក ប៉ុន្តែដោយរដូវភ្លៀងវាពិបាកពេក បានវាកើតមានបញ្ហាដែលដោះមិនទាន់ចេញនេះ ដល់ពេលខ្ញុំទៅបាងកកជួប ឆាវលិត កន្លងទៅនេះបានឱ្យរៀបបាន២ឬ៣ខែ បានដឹកមកតាមប៉ោយប៉ែត យកមកដាក់ខ្ញុំតវ៉ា ដល់ពេលនេះឥឡូវគណៈកម្មការខាងព្រំដែនកំពុងតែដោះស្រាយ ដើម្បីទំលុះ....យកទៅបាញ់ចោលតើ ដល់យកទៅបាញ់ចោល តាប៊ិត គាត់ថាអើ! ហ្អែងសំលាប់អញមក តែមុននឹងសំលាប់អញហ្អែងប្រាប់ប្រពន្ធអញឱ្យមកយកអញ រួចអាក្មេងៗវាអត់ហ៊ានសំលាប់មេចាស់របស់គេ ដល់អញ្ចឹងបាន តាប៊ិត រួចខ្លួនមកប្រជុំកាសែតនៅភ្នំពេញ អញ្ចឹងគឺរឿងនេះវាបាត់ម្ចាស់ការដែរ វាកំហុសដោយកំលាំងតូច... ហ្នឹងវាសន្តិភាពកាំភ្លើងដោយកាំភ្លើងគ្នាប្រមូលកាំភ្លើងដាក់ក្នុងឃ្លាំងហើយ ដើម្បីយកឱកាសធ្វើស្រែធ្វើចំការ អាពួកហ្នឹង

ប្រឹបៗអញ្ចឹងធ្វើអញ្ចឹង ចាត់ការប្រជាជនបានមួយចំនួន ប៉ុន្តែនៅតំបន់នេះមិនជាអីទេ បើយើងដោះស្រាយតោងព្រំដែនជាប់ហើយ ប្រជាជននាំគ្នាធ្វើអី ឥឡូវយើងយល់សង្គមស៊ីវិលបានតែប៉ុណ្ណឹងទេ អត់ហ៊ាននេះទេ កំលាំងរដ្ឋាភិបាលគ្រាន់តែទៅធ្វើអន្តរាគមន៍ដើម្បីនិងជួយដោះស្រាយខាងស្បៀងអាហារ គមនាគមន៍ស្អីៗទេ.... គឺជាមូលដ្ឋានបងប្អូនយើងបង្កើតក្រុមប្រតិបត្តិការប្រដាប់អាវុធ ដើម្បីចូលទៅយកប្រជាពលរដ្ឋឱ្យប្រជាពលរដ្ឋរៀបចំភូមិឃុំរដ្ឋបាលឡើងវិញទាំងអស់ ប៉ុន្តែល្អត្រង់ថាអត់ហ៊ានបាញ់សាលាបាញ់អីទេ ពួកគេហ្នឹងអត់សូវបាញ់អីទេ គេដោះស្រាយល្អណាស់ ហើយតា មុត ហ្នឹងនែ៎ ខ្ញុំមុននឹងទៅញ៉ូវយ៉ក ខ្ញុំឱ្យ បាញ់ ឆ្លងទៅ...ឱ្យលើកបញ្ហានេះបញ្ហានោះមកដោះស្រាយទៅតាមច្បាប់ អាហ្នឹងវាទៅជំលោះផ្ទៃក្នុងទៅវិញ ...ដល់ទៅពេលកើតមានបញ្ហាហ្នឹង អ៊ី ឈាន ចាប់ដាក់គុក៧ខែ អញ្ចឹងរឿងនេះវាអាចទៅជាបញ្ហា ផ្ទាំងផ្ទាក់គ្នា...រួចហើយត្រូវតា ម៉ុក នាំចូលពីក្រោយទៀតវាទៅ អញ្ចឹងឯងខាងនេះលទ្ធភាពនយោបាយ គឺអត់ទៅមុខទៅក្រោយទៅនៅហ្នឹង ប៉ុន្តែសំខាន់ត្រង់ថា ....... ............ បើនៅក្នុងបន្ទាយហ្នឹង មានន័យថាអត់មានគ្រោះថ្នាក់អីកើតឡើងទេ ព្រោះយើងមិនឱ្យប៉ះពាល់ឯណាកំលាំងនេះកំលាំង ព្រោះបន្ទាយតាំងក្រសាំងមិនមែនត្រឹមនេះទេ ខ្ញុំទៅជួយទិញជីឱ្យ សំឡុត អាប្រធានយោធាខេត្តកណ្តាលថា ហ្លែងត្រូវតែលក់ ព្រោះសម្តេចក្រុមព្រះលោកសព្វព្រះទ័យកន្លែងហ្នឹងទៅជួយធ្វើឱ្យទៀតណា៎ ។

**សុន ន័យ** : ដល់ពេលបាននេះបាននោះហើយ លេងវាត់យើងវិញ ។

**សម្តេច** : រួចអាបាញ់ទៅស្លាប់ប្រជាជននៅឯនេះ បាញ់ចេញពីហ្នឹង ហើយបាញ់ចូលវត្តតាំងក្រសាំងហ្នឹងអាកំលាំងទាំងអស់វាមក....កងពលទី៣ ... ដល់ប្រាប់បង ចំរ៉ាត់ យប់ថ្ងៃទី៣១ ខែ៥ ព្រឹកឡើងថ្ងៃទី១ ខែ៦ សមាជិកតា ចាយ ខ្ញុំប្រាប់បង ចំរ៉ាត់ ខ្ញុំថាបងឯងកុំឱ្យសោះ សុំកុំទៅមើលសមាជ ទន់ ចាយ បើប្រើកំលាំងគឺគ្រោះថ្នាក់ហើយ បង ចំរ៉ាត់ ត្រឡប់ទៅវិញនិយាយជាមួយ....យប់ម៉ិញបញ្ជូនមកហើយ មក២៨នាក់បានមកនៅអាពិភពលោកទី២ រួចហើយខ្ញុំបាននិយាយថា បងឥឡូវហ្នឹងកំលាំងកងពលទី៣ បញ្ចេញវាទៅវាអត់មានអីស្របច្បាប់សោះ អត់ទាន់ធ្វើសមាហរណកម្ម ហើយយើងមកបំពាក់អាវុធហ្នឹង ព្រោះប្រធានកងពល អនុកងពល និងសេនាធិការកងពល បានមករាយការណ៍ឱ្យខ្ញុំផ្ទាល់កំលាំងមានប៉ុន្មានអីប៉ុន្មាន ដល់អញ្ចឹងគេអត់ទុកចិត្តថ្ងៃទី៤ ខែ៦ គេដកអាវុធបញ្ជូនទៅនៅក្នុងវត្ត ដល់ថ្ងៃទី៥ហ្នឹង ល្ងាចថ្ងៃទី៥ បុក១០គ្រាប់ ឥឡូវលោកប្តឹងទារលុយបុក១០គ្រាប់ចូលក្នុងវត្តហ្នុងស្លាប់អស់ប៉ុន្មានសុទ្ធតែខ្មែរក្រហមបង្កប់ ។ មានអីឱ្យខ្ញុំជួយទេ? ជាថវិកាអី ត្រូវការទៅមើលប្រពន្ធមើលកូនអី?

**សុន ន័យ** : ខ្ញុំវាអញ្ចេះប្រាក់ខែសភានោះបើក២០ខែ យកទៅធ្វើទុនជាមួយអង្គការសហជីព៣ ដល់ទៅមានអីអានោះលុយវាអត់ឱ្យម្តងនេះ២ម៉ឺន ...អានេះលុយវាចេះតែចាយបាត់ មិនទាន់បានទាក់ទង ចាំមើលទាក់ទងទៅវាក្រែងលោវាឱ្យខ្លះ ប៉ុន្តែវាយកលេសហើយថា បាត់ម៉ាស៊ីនបាត់អីអស់ហើយ ទីណាត់ទីណែងអស់ហើយ ។

**សម្ដេច** : បើអញ្ចឹងយកអានេះទៅ នេះក្រែងលោឧបត្ថម្ភណា! មានការអីនែ៎ ប៉ុន្តែខែក្រោយខ្ញុំទៅតូក្យូថ្ងៃ៤ មុនដំបូងថាចេញទៅថ្ងៃ៥ ប៉ុន្តែឥឡូវហ្នឹងក្រែងលោកប៉ាលហោះវានេះ ថ្ងៃ៥ខ្ញុំទៅដល់តូក្យូ ថ្ងៃ៦ ជួបនាយករដ្ឋមន្ត្រីជប៉ុន ល្ងាចថ្ងៃទី៦ហ្នឹងដែរចូលពេទ្យ ហើយមានការអីហៅទូរស័ព្ទត្រង់មក ដឹងលេខទូរស័ព្ទថ្មីឬនៅ?

**សុន ឆ័យ** : ធ្លាប់វាយអាចាស់ហ្នឹង អាលេខ ៩១៩ ៣៣៣ ។

**សម្ដេច** : ឥឡូវវាយអា ០១២ ៨៨៨ ៧៧៧ និង ០១២ ៨០០ ០០១ មានការអីវាយអាហ្នឹងត្រង់មក យប់ខ្ញុំច្រើននៅអាប្រាំបីសូនសូន (៨០០) ។

**សុន ឆ័យ** : បាទ! បងស្រីអញ្ជើញទៅណា ?

**សម្ដេច** : ម៉ិញនៅ ត្រង់ណាទេហ្នឹង រៀបចំនេះនោះ ។

**សុន ឆ័យ** : ទៅស្អែក អាហ្នឹងក៏សំខាន់ដែរ។

**សម្ដេច** : ស្អែកផ្អាកវិញ អត់ទេ គាត់ចូលពេទ្យម៉ោង ៣ ។

**សុន ឆ័យ** : អូ!

**សម្ដេច** : ហើយកំពុងតែណាត់គ្នាជួបគ្នាបន្ថែមនេះទៀត។ មកជាមួយពីណាម៉ិញ ណារ៉ូ ឬ ?

**សុន ឆ័យ** : អត់ទេ ណារ៉ូ គេទៅខាង...។

**សម្ដេច** : បានពីណាជូនមក ឡាននៅឯណា ? អោយឡានចូលមកក្នុងមក។

**សុន ឆ័យ** : ... ប៉ូលីស ... ប៉ូលីសហ្នឹងគេមិនបានធ្វើអីទេ។

**សម្ដេច** : ប៉ូលីសសេដ្ឋកិច្ច ?

**សុន ឆ័យ** : ..... មិនដឹងប៉ូលីសអីទេ ......។

**សម្ដេច** : ផ្លូវនេះពិបាកណាស់ ប៉ុន្តែឥឡូវគេដេញថ្លៃហើយ ចាក់នេះ។ រើមកនៅនេះធូរបន្តិចខ្ញុំ តិចទៀតបានមកឡើងនៅផ្ទះថ្មីហើយ។

**សុន ឆ័យ** : បាទ! ចាំមើលមកវិញ ចាំមកជួបបងទៀត។

**សម្ដេច** : ហ្នឹងហើយ ។

---